ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.




# របាយការណ៍ប្រចាំឆ្នាំ ២០២៥

# អគារការិយាល័យកណ្ដាលថ្មី





ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.
ការិយាល័យកណ្តាល
Head Quarter

# ផលិតផល និងសេវាកម្ម

គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផ្តល់នូវកញ្ចប់សេវាហិរញ្ញវត្ថុច្រើនបែបយ៉ាងមានដូចជា ឥណទានអាជីវកម្ម ឥណទានគេហដ្ឋាន ឥណទានកសិកម្ម ឥណទានបុគ្គលិក ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឥណទានសិក្សា ឥណទាននិយោជិត និងឥណទានយានយន្ត និងបរិក្ខារប្រើប្រាស់ ជាមួយនឹងអត្រាការប្រាក់ទាប និងប្រកួតប្រជែងក្នុងទីផ្សារបច្ចុប្បន្ន។



# ការបង្កើតផលិតផលថ្មី

ផលិតផល ថ្មី

គ្មានទ្រព្យធានា



## ឥណទានយានយន្ត និងបរិក្ខារប្រើប្រាស់

### គោលដៅអតិថិជន

ផ្តល់ជូនសម្រាប់អតិថិជនទូទៅ អតិថិជនចាស់ និងអតិថិជនថ្មី ដែលមានតម្រូវការទិញរបស់របរប្រើប្រាស់ផ្សេងៗដូចជា ម៉ូតូ ម៉ូតូកង់បី គ្រឿងបរិក្ខារប្រើប្រាស់ក្នុងផ្ទះ និងឧបករណ៍អេឡិចត្រូនិកជាដើម។

### ប្រភេទរូបិយប័ណ្ណ

ប្រាក់រៀល និង ដុល្លារ

### ទំហំឥណទាន

រហូតដល់ ៥,០០០ ដុល្លារ

### រយៈពេលសង

រហូតដល់ ៤ ឆ្នាំ

# ចំណាប់អារម្មណ៍របស់លោកប្រធានក្រុមប្រឹក្សាភិបាល



**លោក ច្រឹក ផល្លី**
ប្រធានក្រុមប្រឹក្សាភិបាល

ជាដំបូង ខ្ញុំសូមជម្រាបជូនថា គិតមកដល់ឆ្នាំ២០២៥ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បាន បើកប្រតិបត្តិការអាជីវកម្មរបស់ខ្លួនមានរយៈពេល ១០ឆ្នាំមកហើយ នេះក៏ជាឆ្នាំដែលគ្រឹះស្ថានបានធ្វើការផ្លាស់ប្តូរទីតាំងការិយាល័យកណ្តាលថ្មីរបស់ខ្លួន ដែលមានទីកន្លែងធំទូលាយល្អប្រសើរជាងមុន សម្រាប់បន្តផ្តល់នូវសេវាកម្មដ៏ល្អជូនអតិថិជន និងដៃគូសហការនានា។ ជាពិសេសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះធនាគារជាតិនៃកម្ពុជា និងក្រសួងពាក់ព័ន្ធដែលបានផ្តល់ការអនុញ្ញាតជាផ្លូវការសម្រាប់ការផ្លាស់ប្តូរនេះ ដែលពិតជាបានមើលឃើញពីការខំប្រឹងប្រែង និងសារៈសំខាន់របស់យើងខ្ញុំដែលជាផ្នែកមួយសម្រាប់ការគាំទ្រដល់វិស័យធនាគារ និងហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។

នៅក្នុងឆ្នាំ២០២៥ ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅតែមានការប្រឈមនឹងភាពតានតឹងភូមិសាស្ត្រ នយោបាយ បញ្ហាអូសបន្លាយនៃសង្គ្រាមរវាងប្រទេសរុស្សីនិងអ៊ុយក្រែន សង្គ្រាមរវាងសហរដ្ឋអាមេរិក និងប្រទេសអ៊ីរ៉ង់ ដែលនាំឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចស្ទើរតែគ្រប់ប្រទេសនៅលើពិភពលោក ហើយចុងក្រោយនេះសង្គ្រាមឈ្លានពានព្រំដែនពីប្រទេសថៃមកលើប្រទេសកម្ពុជា និងការប្រឈមនឹងការរីករាលដាលជាសកលនៃឧក្រិដ្ឋកម្មសាយប័រនៃបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាទទួលរងនូវផលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះប្រទេស ហើយអាចមានហានិភ័យដល់ប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ ជាពិសេសការធ្វើពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិនានា។ យើងឃើញថា កំណើនសេដ្ឋកិច្ចពិភពលោកសម្រាប់ឆ្នាំ២០២៥ បានព្យាករណ៍ក្នុងអត្រា ៣,២% ដែលក្នុងនោះប្រទេសកំពុងអភិវឌ្ឍន៍ក្នុងអត្រា ១,៦% ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍បានកើនក្នុងអត្រា ៤,២% និងសេដ្ឋកិច្ចតំបន់អាស៊ានបានថយចុះត្រឹមអត្រា ៤,៣% និងអតិផរណាពិភពលោកបានថយចុះនៅត្រឹម ៤,២% បើយោងតាមរយៈការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ សម្រាប់ឆ្នាំ២០២៥ ត្រូវបានប៉ាន់ស្មានថាមានកំណើនក្នុងអត្រា ៥% និងអត្រាអតិផរណាមានត្រឹមកម្រិត ២,៥% ជាអត្រាមួយទាប ដែលជំរុញដោយការនាំចេញសម្លៀកបំពាក់ដ៏រឹងមាំ និងភាពធន់នៃវិស័យកសិកម្ម ទោះបីជាប្រឈមមុខនឹងឧបសគ្គពីបំណុលឯកជនខ្ពស់ តម្រូវការអចលនទ្រព្យខ្សោយ និងភាពមិនប្រាកដប្រជានៃពាណិជ្ជកម្មសកល

ក៏ដោយ។ អតិថិជនណាអាចគ្រប់គ្រងបាន ហើយការវិនិយោគផ្ទាល់ពីបរទេសនៅតែរឹងមាំ ទោះបីជាគណនីចរន្តបានផ្លាស់ប្តូរទៅជាឱនភាព ក៏ដោយ។

ចំពោះទំនុកចិត្តមកលើប្រព័ន្ធធនាគារ និងមីក្រូហិរញ្ញវត្ថុនៃប្រទេសកម្ពុជានូវតែបន្តរក្សាបានវឌ្ឍនភាព និងស្ថិរភាព តាមរយៈការគាំទ្រពីសាធារណជន អតិថិជនទូទៅ និងអ្នកវិនិយោគក្នុងស្រុក។ ចំណុចនេះយើង អាចមើលឃើញថាប្រព័ន្ធធនាគារ និងមីក្រូហិរញ្ញវត្ថុ ពិតជាបានរងផលប៉ះពាល់ដែលធនាគារជាតិនៃកម្ពុជា បានបន្តតាមដានស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ បន្តពង្រឹងក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិ ព្រមទាំងពង្រីកសហប្រតិបត្តិការក្នុងស្រុកនិងក្រៅស្រុក ជំរុញវិធានការការទប់ស្កាត់និងបង្ការហានិភ័យនានា និងវិធានការអនុគ្រោះបទប្បញ្ញត្តិត្រូវបានដាក់ចេញ។ ក្នុងស្ថានភាពនេះឃើញថា ការកើនឡើងនូវបំណុលយឺតយ៉ាវក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ហើយគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក៏មានការកើនឡើង ដូចគ្នាដែលទាមទារការខិតខំប្រឹងប្រែងដោះស្រាយ និងអនុវត្តនូវវិធានការនានាដែលបានដាក់ចេញពី ធនាគារជាតិនៃកម្ពុជា។

ទោះបីមានបញ្ហាប្រឈមដែលបានជះឥទ្ធិពលមួយចំនួនដល់សេដ្ឋកិច្ចកម្ពុជា និងវិស័យធនាគារ និងហិរញ្ញវត្ថុក៏ដោយ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅតែបានខិតខំប្រឹងប្រែងអនុវត្តកិច្ចការងារ និងមានវិធានការដោះស្រាយលើហានិភ័យមួយចំនួន ជាពិសេសពង្រឹងលើគុណភាពឥណទានបន្ថែមទៀត និងកាត់បន្ថយការចំណាយណាដែលមិនចាំបាច់ ស្របទៅតាមផែនការយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន ហើយគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក៏បានផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ខ្លួនក្នុងកម្រិតក្រុមប្រឹក្សាភិបាល ដើម្បីបន្តការត្រួតពិនិត្យ តាមដាន និងផ្តល់អនុសាសន៍ក្នុងប្រតិបត្តិការអាជីវកម្មឱ្យកាន់តែមានប្រសិទ្ធភាព។ ទោះជាស្ថិតនៅស្ថានភាពលំបាកនេះក៏ដោយតាមរយៈរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៥ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅតែអាចរក្សាប្រាក់ចំណេញរបស់ខ្លួនបានចំនួន ២៣២.១២៥ ដុល្លារអាមេរិក ជាមួយនឹងទ្រព្យសកម្មចំនួន ១៥.៨៨៦.៦៤៥ ដុល្លារអាមេរិក។ ទោះបីការចំណេញនេះមិនទាន់ស្របទៅតាមផែនការកំណត់ តែក៏ជាលទ្ធផលល្អមួយដែលបានបង្ហាញពីការចូលរួមសហការពីគណៈគ្រប់គ្រង បុគ្គលិកទាំងអស់ និងពិសេសផ្នែកឥណទានផ្ទាល់ ដែលបានខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រង និងដោះស្រាយបំណុលយឺតយ៉ាវឱ្យបានទាន់ពេលវេលា។

ក្នុងនាមប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អតិថិជននៅតែមានសុច្ឆន្ទៈក្នុងការប្រើប្រាស់សេវា និងផលិតផលរបស់គ្រឹះស្ថាន ដើម្បីចូលរួមចំណែកអភិវឌ្ឍអាជីវកម្ម និងធនធានមនុស្សជំនាន់ក្រោយក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសភាគទុនិកជប៉ុនរបស់យើងខ្ញុំ តែងតែផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ព្រមទាំងសមាជិកក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ នាយករងប្រតិបត្តិ គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ របស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សម្រាប់ការគាំទ្រ និងការខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួន និងការអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះធនាគារជាតិនៃកម្ពុជា ក្រសួងពាក់ព័ន្ធ និងដៃគូសហប្រតិបត្តិការនានា ដែលតែងតែផ្តល់ការសហការការគាំទ្រ និងអនុសាសន៍នានាដល់គ្រឹះស្ថានយើងខ្ញុំ លើចំណុចខ្វះខាតមួយចំនួនបន្ថែមទៀត ដែលគ្រឹះស្ថាននូវតែយកចិត្តទុកដាក់លើចំណុចខ្វះខាតទាំងនោះ ដើម្បីពង្រឹងលើវិធានការអនុវត្ត និងពិនិត្យចាត់ចែងបន្តនូវរាល់ផែនការសកម្មភាពការងារ ទាំងអស់នោះឱ្យកាន់តែមានប្រសិទ្ធភាព និងប្រកបដោយតម្លាភាពរហូតមកដល់ពេលបច្ចុប្បន្ន និងនាពេលអនាគត។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ វិបុលសុខ ចូរកើតមានដល់លោកអ្នក និងក្រុមគ្រួសារនូវ សេចក្តីសុខចម្រើន សុខភាពល្អជោគជ័យគ្រប់ភារកិច្ចការងារ និងទេវតាឆ្នាំថ្មី ឆ្នាំមមី ( ឆ្នាំ២០២៦ ) តាមថៃរក្សាជានិច្ចនិរន្តរតរៀងទៅ។



លោក ច្រឹក ផល្លី
ប្រធានក្រុមប្រឹក្សាភិបាល

# ចំណាប់អារម្មណ៍របស់លោកនាយកប្រតិបត្តិ



**លោក អ៊ុំ ពិសិដ្ឋ**
នាយកប្រតិបត្តិ

ជូនចំពោះអតិថិជន និងដៃគូពាណិជ្ជកម្មជាទីគោរព!

សូមជម្រាបជូនថា គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី បានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបសកម្មភាពអាជីវកម្មនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។ ដោយមើលឃើញពីដំណើរការជាវិជ្ជមាននៃការប្រតិបត្តិ និងការគ្រប់គ្រង ព្រមទាំងផែនការយុទ្ធសាស្ត្រវែងឆ្ងាយទៅថ្ងៃអនាគតរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍សម្រាប់ប្រកបអាជីវកម្មជាផ្លូវការមកឱ្យគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី ជំនួសឱ្យអាជ្ញាបណ្ណដែលមានកំណត់រយៈពេល ៣ឆ្នាំ ហើយក៏បានអនុញ្ញាតក្នុងការបង្កើតសាខាថ្មីមួយបន្ថែមទៀត គឺសាខាក្រុងដូនកែវ ខេត្តតាកែវ ដោយបានទទួលអាជ្ញាបណ្ណស្របច្បាប់ពីធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣។ នៅក្នុង ឆ្នាំ២០២៥ គ្រឹះស្ថានបានធ្វើការផ្លាស់ប្តូរទីតាំងការិយាល័យកណ្តាលថ្មីរបស់ខ្លួន ដែលបានចេញសន្លឹកអាជ្ញាបណ្ណថ្មីពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ ហើយក៏ជាឆ្នាំដ៏ពិសេសគម្រប់ខួប ១០ឆ្នាំ ដែលគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី បានបើកប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

ដោយស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា មិនទាន់មានភាពល្អប្រសើរនៅឡើយ ហើយបើក្រឡេកមកមើលស្ថានភាពនៃវិស័យធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ គ្រឹះស្ថានបង់រំលស់ ព្រមទាំងគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី នៅក្នុងឆ្នាំ២០២៥ ក៏នៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួន ជាពិសេសទៅលើការគ្រប់គ្រងគុណភាពឥណទានដោយបំណុលយឺតយ៉ាវមានការកើនឡើង និងតម្លៃអចលនទ្រព្យមានការធ្លាក់ចុះដែលប្រឈមទៅនឹងបំណុលយឺតយ៉ាវ។ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី បាន និងកំពុងបានបម្រើសេវាជូនអតិថិជន និងបម្រើការងារនៅការិយាល័យកណ្តាល និងសាខាមានចំនួន ០៥ ទីតាំងរួមមានការិយាល័យកណ្តាល (សាខាការិយាល័យកណ្តាល) សាខាខណ្ឌព្រែកព្នៅ សាខាខណ្ឌពោធិ៍សែនជ័យ សាខាក្រុងច្បារមន (ខេត្តកំពង់ស្ពឺ) និងសាខាក្រុងដូនកែវ (ខេត្តតាកែវ) ហើយជាក់ស្តែង ចាប់ពីឆ្នាំ២០២៤ មកដល់បច្ចុប្បន្ន គ្រឹះស្ថានមិនបានបើកសាខាថ្មីបន្ថែមទៀតនោះទេ។

សមិទ្ធផលដែលទទួលបានសង្ខេបៗគិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ របស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី ដូចខាងក្រោម៖

. បុគ្គលិកសរុបចំនួន ៩៥នាក់ ស្ត្រីចំនួន ២៧នាក់ និងបុរសចំនួន ៦៨នាក់
. អតិថិជនដែលបាន និងកំពុងទទួលកម្ចីមានសរុប ១.២៤៧ នាក់
. ផលបត្រឥណទានសរុប ១៤.៧៣០.៥១២ ដុល្លារអាមេរិក
. ទ្រព្យសកម្មសរុបចំនួន ១៥.៨៨៦.៦៤៥ ដុល្លារអាមេរិក
. ប្រាក់ចំណេញសម្រាប់ឆ្នាំ២០២៥ ចំនួន ២៣២.១២៥ ដុល្លារអាមេរិក
. ហានិភ័យនៃផលបត្រឥណទាន (ធំជាង៣០ថ្ងៃ) ចំនួន ២០,៧៨%

. បំណុលយឺតយ៉ាវកាត់ចេញពីបញ្ជីមានចំនួន 0%
. អនុបាតសន្ទនីយភាព (ប្រកាស) ចំនួន >១00%
. អនុបាតសាធនភាព (ប្រកាស) ចំនួន ៤៥%
. ដើមទុនអប្បបរមា (ប្រកាស) ចំនួន ៧.000.000 ដុល្លារអាមេរិក
. មូលនិធិផ្ទាល់សុទ្ធ (ប្រកាស) ចំនួន ៧.២២០.១៦១ ដុល្លារអាមេរិក
. ការផ្តល់ឥណទានជារូបិយវត្ថុជាតិ (ប្រកាស) ចំនួន ១៤,១៥%

បើទោះបីគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មិនទាន់មានការិយាល័យប្រតិបត្តិការឱ្យបានទូលំទូលាយនៅទូទាំងប្រទេសកម្ពុជា ក៏ចក្ខុវិស័យរបស់យើងខ្ញុំត្រូវតែខិតខំអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជា គ្រឹះស្ថានហិរញ្ញវត្ថុឈានមុខមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពក្នុងពេលបច្ចុប្បន្ន ក៏ដូចពេលអនាគតតាមរយៈការធ្វើឱ្យមានលំនឹងស្ថិរភាព តម្លាភាពលើផ្នែកទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា និងផែនការយុទ្ធសាស្ត្ររយៈពេលវែងដែលនឹងពង្រឹងការអនុវត្តលើតំបន់ប្រតិបត្តិការដែលមានស្រាប់ និងពង្រីកតំបន់ប្រតិបត្តិការឱ្យបានទូលំទូលាយបន្ថែមទៀតនៅតាមបណ្តាខេត្តផ្សេងៗទៀតជាដំណាក់កាលៗនាពេលខាងមុខ ដោយបត់បែនតាមស្ថានភាពសេដ្ឋកិច្ច និងប្រព័ន្ធនៃការគ្រប់គ្រង ដែលជាបំណងប្រាថ្នាដ៏សុចរិត ក៏ដូចជាគោលដៅរបស់គ្រឹះស្ថានយើងខ្ញុំផងដែរ។

នាប៉ុន្មានឆ្នាំចុងក្រោយនេះសម្រាប់ការបំពេញតម្រូវការអតិថិជន យើងនៅតែបន្តការយកចិត្តទុកដាក់លើការពង្រឹងប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន បង្កើត និងបច្ចុប្បន្នភាពលើគោលការណ៍ និងនីតិវិធីនានា ការគ្រប់គ្រងដោះស្រាយលើឥណទានយឺតយ៉ាវ ពង្រឹងសមត្ថភាពបុគ្គលិក (តាមរយៈការបណ្តុះបណ្តាលខាងក្នុង និងខាងក្រៅ) ការគ្រប់គ្រងនិងចាត់ចែងការចំណាយឱ្យមានប្រសិទ្ធភាព កែសម្រួលនូវការងារ និងរបាយការណ៍មួយចំនួនដែលអាចយកចេញពីប្រព័ន្ធ និងការកែសម្រួលរចនាសម្ព័ន្ធក្នុងកម្រិតនាយកដ្ឋាន ដើម្បីឱ្យការប្រតិបត្តិ និងការត្រួតពិនិត្យកាន់តែមានភាពរឹងមាំ និងប្រសិទ្ធភាពនៃការអនុវត្តស្របតាមការប្រតិបត្តិតាមច្បាប់ ឬបទប្បញ្ញត្តិដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា និងក្រសួងពាក់ព័ន្ធ។

គ្រឹះស្ថានរបស់យើងខ្ញុំនឹងរិះរកវិធីក្នុងការផ្តល់ជូននូវសេវាដ៏សម្បូរបែប និងប្រកបដោយភាពច្នៃប្រឌិតខ្ពស់លើដំណោះស្រាយហិរញ្ញវត្ថុថ្មីៗ ជូនចំពោះអតិថិជនចាស់ និងថ្មីទាំងអស់។ កន្លងមកដើម្បីបំពេញតម្រូវការរបស់អតិថិជន គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតផលិតផលសេវាហិរញ្ញវត្ថុជាច្រើនដែលរួមមាន ឥណទានអាជីវកម្ម ឥណទានកសិកម្ម ឥណទានគេហដ្ឋាន ឥណទានសម្រាប់ប្រើប្រាស់ ឥណទានបុគ្គលិក ឥណទានសម្រាប់ការសិក្សា និងឥណទាននិយោជិត ហើយក្នុងឆ្នាំ២០២៥ បានបង្កើតផលិតផលឥណទានថ្មីមួយបន្ថែមទៀតគឺ ឥណទានយានយន្ត និងបរិក្ខារប្រើប្រាស់ សម្រាប់តម្រូវការ ជាក់ស្តែងរបស់អតិថិជន។ ចំពោះឥណទានបុគ្គលិក និងឥណទានសម្រាប់ការសិក្សា ត្រូវបានផ្តល់ជូនក្នុងអត្រាការប្រាក់ទាបបំផុត ជាមួយនឹងសេវាល្អឥតខ្ចោះ ដែលមិនធ្លាប់មានក្នុងគោលដៅចូលរួមលើកស្ទួយផ្នែកសង្គម គាំទ្រជីវភាពគ្រួសាររបស់បុគ្គលិក និងអភិវឌ្ឍនូវវិស័យធនធានមនុស្ស។

វិស័យធនាគារ និងហិរញ្ញវត្ថុ នៅតែមានការប្រឈម ហើយក៏បានប៉ះពាល់ដល់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ដោយប្រាក់ចំណេញទាបជាងផែនការកំណត់ និងស្ថានភាពឥណទានយឺតយ៉ាវនៅតែបន្តការកើនឡើង។ ប្រព័ន្ធធនាគារនិងមីក្រូហិរញ្ញវត្ថុនៃប្រទេសកម្ពុជា នូវតែអាចគ្រប់គ្រងបាន និងបន្តការគាំទ្រពីសាធារណជន ដែលអាចធ្វើឱ្យសេដ្ឋកិច្ចក្នុងស្រុករបស់កម្ពុជានឹងវិលទៅរកភាពប្រក្រតីឡើងវិញ ដោយមុខរបរអាជីវកម្មនានា និងតម្លៃអចលនទ្រព្យអាចនឹងមានដំណើការល្អប្រសើរឡើងវិញនៅថ្ងៃខាងមុខឆាប់ៗ យើងសង្ឃឹម និងជឿជាក់ថាធនាគារជាតិនៃកម្ពុជា នឹងបន្តភាពរឹងមាំរបស់ខ្លួន ហើយចូលរួមចំណែកពីគ្រឹះស្ថានយើងខ្ញុំនឹងបន្តប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងក្លាយជាមាគ៌ាសម្រាប់អ្នកជំនាន់ក្រោយកម្ពុជាដែលសម្រេចយកភាពត្រឹមត្រូវ ស្មើគ្នា និងរក្សាឱ្យបាននូវតម្លាភាពជាមូលដ្ឋានក្នុងវិស័យសេវាហិរញ្ញវត្ថុ។ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានការគាំទ្រមូលនិធិពីភាគទុនិកឯកកម្មសិទ្ធិពីប្រទេសជប៉ុន ដែលយើងខ្ញុំអាចគ្រប់គ្រង និងចាត់ចែងប្រកបដោយភាពស្ទាត់ជំនាញ និងផ្តល់សេចក្តីសម្រេចចិត្តបានយ៉ាងឆាប់រហ័ស ដើម្បីបំពេញតាមតម្រូវការអតិថិជន។ ដើម្បីឱ្យ “សុបិនក្លាយជាការពិត” ទាំងអតិថិជន និងគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី យើងខ្ញុំរីករាយស្វាគមន៍សហការក្នុងការផ្តល់សេវាហិរញ្ញវត្ថុយ៉ាងកក់ក្តៅ និងជាទីទុកចិត្តបំផុតជូនអតិថិជនទាំងអស់នូវសេវាឥណទានយ៉ាងសម្បូរបែបគ្រប់ពេលវេលាដែលត្រូវការ។

ជាទីបញ្ចប់ ក្នុងនាមជានាយកប្រតិបត្តិ និងគណៈគ្រប់គ្រងរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ខ្ញុំសូមគោរពថ្លែងអំណរគុណដល់អតិថិជន ភាគទុនិកជប៉ុន ក្រុមប្រឹក្សាភិបាល នាយករងប្រតិបត្តិ គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ដែលតែងតែផ្តល់ការគាំទ្រ និងការខិតខំប្រឹងប្រែងក្នុងការអនុវត្តការងារទៅតាមការទទួលខុសត្រូវ និងផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថានកន្លងមក ក៏ដូចជាធនាគារជាតិនៃកម្ពុជា និងក្រសួងពាក់ព័ន្ធដែលតែងតែផ្តល់នូវអនុសាសន៍ល្អៗ កិច្ចសហការ និងការគាំទ្រនានាដល់គ្រឹះស្ថានយើងខ្ញុំ។ ខ្ញុំសូមគោរពជូនពរដល់ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកគ្រូ- អ្នកគ្រូទាំងអស់ សូមទទួលបានជោគជ័យក្នុងភារកិច្ចការងារ សុខភាពល្អ និងជួបប្រទះនូវពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងទេវតាឆ្នាំថ្មីតាមថែរក្សាកុំបីឃ្លៀងឃ្លាតឡើយ។

សូមសុបិនរបស់លោកអ្នកក្លាយជាការពិត។



លោក អ៊ុំ ពិសិដ្ឋ
នាយកប្រតិបត្តិ

# មាតិកា


| | ទំព័រ |
|---|---|
| អគារការិយាល័យកណ្ដាលថ្មី | ០១ |
| ផលិតផល និងការបង្កើតផលិតផលថ្មី | ០៣ |
| ចំណាប់អារម្មណ៍របស់លោកប្រធានក្រុមប្រឹក្សាភិបាល | ០៥ |
| ចំណាប់អារម្មណ៍របស់លោកនាយកប្រតិបត្តិ | ០៧ |
| មាតិកា | ០៩ |
| **សមិទ្ធផលសំខាន់ៗ** | ១១ |
| លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ | ១២ |
| សមិទ្ធផលប្រតិបត្តិការសំខាន់ៗ | ១៤ |
| លទ្ធផលសង្ខេបផ្នែកធនធានមនុស្ស | ១៥ |
| **អំពី ហ្វូតាបា** | ១៧ |
| ផែនទីតំបន់ប្រតិបត្តិការ | ១៨ |
| ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា | ២០ |
| ប្រវត្តិសង្ខេបរបស់ ហ្វូតាបា | ២១ |
| ទស្សនៈវិស័យ  បេសកកម្ម និងតម្លៃស្នូល | ២៣ |
| ស្លាកសញ្ញារបស់ ហ្វូតាបា | ២៤ |
| **អភិបាលកិច្ច** | ២៥ |
| ម្ចាស់ភាគទុនិក និងដើមទុន | ២៦ |
| រចនាសម្ព័ន្ធ | ២៧ |
| ក្រុមប្រឹក្សាភិបាល | ២៨ |
| គណៈគ្រប់គ្រង | ៣០ |
| **ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម** | ៣៣ |
| ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម | ៣៤ |
| សវនកម្មផ្ទៃក្នុង | ៣៥ |
| **សមិទ្ធផលអាជីវកម្ម** | ៣៧ |
| សមិទ្ធផលឥណទានតាមវិស័យ | ៣៨ |
| សមិទ្ធផលឥណទានតាមផលិតផល | ៣៩ |
| ចំណាត់ថ្នាក់ប្រភេទឥណទាន | ៤០ |
| ចំណាត់ថ្នាក់ប្រភេទផលិតផល | ៤០ |
| **ការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពបុគ្គលិក** | ៤១ |
| ការបណ្ដុះបណ្ដាលខាងក្នុង | ៤២ |
| ការបណ្ដុះបណ្ដាលខាងក្រៅ | ៤៣ |
| សិក្ខាសាលាប្រចាំឆ្នាំ | ៤៤ |
| **របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មឯករាជ្យ** | ៤៥ |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ៤៦ |
| របាយការណ៍របស់សវនករឯករាជ្យ | ៤៩ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៥១ |
| របាយការណ៍ចំណេញ ខាត និងចំណូលពេញលេញផ្សេងៗ | ៥២ |
| របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន | ៥៣ |
| របាយការណ៍លំហូរសាច់ប្រាក់ | ៥៤ |
| **ដៃគូសហប្រតិបត្តិការរបស់ ហ្វូតាបា** | ៥៥ |
| ដៃគូ | ៥៥ |
| ម្ចាស់កម្ចី | ៥៥ |




## ស្កេនត្រង់នេះ

ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយ
គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

# សមិទ្ធផលសំខាន់ៗ

- លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ
- សមិទ្ធផលប្រតិបត្តិការសំខាន់ៗ
- លទ្ធផលសង្ខេបផ្នែកធនធានមនុស្ស

# លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ដុល្លារអាមេរិក)

| | ២០២៥ | ២០២៤ |
|---|---|---|
| **ទ្រព្យសកម្មសរុប** | | |
| សាច់ប្រាក់ក្នុងដៃ និងសាច់ប្រាក់នៅធនាគារ | ៥៥០.៧៧១ | ៤១៦.៦៣៧ |
| សមតុល្យប្រាក់កម្ចីសរុប | ១៤.៨៧៥.៧៤៣ | ១៤.៧៩៨.៦២០ |
| ទ្រព្យសម្បត្តិ និងឧបករណ៍-សម្ភារៈសរុប | ១៧០.០៧០ | ១១៧.៤២៨ |
| ទ្រព្យសម្បត្តិផ្សេងៗ | ២៩០.០៦១ | ២១៦.៧៩៤ |
| **សរុបទ្រព្យសកម្ម** | **១៥.៨៨៦.៦៤៥** | **១៥.៥៤៩.៤៧៩** |
| **បំណុល** | | |
| បំណុលផ្សេងៗ និងសំវិធានធន | ៥៨៩.៤៧៤ | ៤៨៤.៤៣៣ |
| កម្ចីរយៈពេលវែង និងកម្ចីរយៈពេលខ្លី | ៥.៥៣៧.១៨២ | ៥.៥៣៧.១៨២ |
| **បំណុលសរុប** | **៦.១២៦.៦៥៦** | **៦.០២១.៦១៥** |
| **មូលធនភាគទុនិក** | | |
| ដើមទុន | ៧.០០០.០០០ | ៧.០០០.០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ២.៨៩២.៨៨៨ | ២.៥០៨.៩៩០ |
| ប្រាក់ចំណេញរក្សាទុក | (១៣២.៨៩៩) | ១៨.៨៧៤ |
| មូលធនសរុប | ៩.៧៥៩.៩៨៩ | ៩.៥២៧.៨៦៤ |
| **សរុបបំណុល និងមូលធនភាគទុនិក** | **១៥.៨៨៦.៦៤៥** | **១៥.៥៤៩.៤៧៩** |

## របាយការណ៍លទ្ធផលពេញលេញ (ដុល្លារអាមេរិក)

| | ២០២៥ | ២០២៤ |
|---|---|---|
| ចំណូលការប្រាក់ និងថ្លៃសេវាផ្សេងៗ | ២.០២៧.១៩៥ | ២.០១៤.២៥៩ |
| ចំណាយប្រតិបត្តិការ | (១.៧៩៥.០៧០) | (១.៧០៧.២៤១) |
| **ប្រាក់ចំណេញសុទ្ធ** | **២៣២.១២៥** | **៣០៧.០១៨** |

## សូចនាករសំខាន់ៗ (ដុល្លារអាមេរិក)

| | ២០២៥ | ២០២៤ |
|---|---|---|
| អនុបាតសោធនភាព | ៦៣% | ៦៣% |
| ប្រាក់ចំណេញសុទ្ធ ធៀបមធ្យមភាគទ្រព្យសកម្ម (RoA) | ១% | ២% |
| ប្រាក់ចំណេញសុទ្ធ ធៀបមធ្យមភាគមូលធន (RoE) | ២% | ៣% |

### សរុបទ្រព្យសកម្ម

**១៥.៨៨៦.៦៤៥**

( ដុល្លារអាមេរិក )

### បំណុលសរុប

**៦.១២៦.៦៥៦**

( ដុល្លារអាមេរិក )

### មូលធនសរុប

**៩.៧៥៩.៩៨៩**

( ដុល្លារអាមេរិក )



# សមិទ្ធផលប្រតិបត្តិការសំខាន់ៗ

| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ដុល្លារអាមេរិក) | ២០២៥ | ២០២៤ |
|---|---|---|
| ចំនួនការិយាល័យសាខា | ៥ | ៥ |
| ចំនួនខេត្តប្រតិបត្តិការ | ១២ | ១២ |
| ចំនួនស្រុកប្រតិបត្តិការ | ៦០ | ៥៦ |
| ចំនួនឃុំប្រតិបត្តិការ | ២២៩ | ១៩៨ |
| ចំនួនភូមិប្រតិបត្តិការ | ៦១៤ | ៥១០ |
| ចំនួនបុគ្គលិកសរុប | ៩៥ | ៩៧ |
| ចំនួនមន្ត្រីឥណទាន | ៣០ | ៣០ |
| មន្ត្រីឥណទានធៀបនឹងបុគ្គលិកសរុប | ៣២% | ៣១% |
| ចំនួនអតិថិជនសកម្ម | ១.១៣៥ | ៩២៨ |
| ចំនួនគណនីឥណទានសកម្ម | ១.២៤៧ | ១.០១៥ |
| ចំនួនគណនីឥណទានជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់ | ៤២ | ៣៤ |
| សំពៀតឥណទានសរុប (ដុល្លារអាមេរិក) | ១៤.៨៧៥.៧៤៣ | ១៤.៧៩៨.៦២០ |
| សំពៀតឥណទានជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់ (ដុល្លារអាមេរិក) | ៤៩១.០១៧ | ៥១១.៤៧៥ |
| សំពៀតឥណទានជាមធ្យមក្នុងបុគ្គលិកម្នាក់ (ដុល្លារអាមេរិក) | ១៥៥.០៥៨ | ១៥៨.១៨៨ |
| ទំហំឥណទានជាមធ្យម (ដុល្លារអាមេរិក) | ១១.៨១៣ | ១៥.១១៧ |
| ហានិភ័យឥណទានធំជាង ៣០ថ្ងៃ | ២០,៧៨% | ១៩,៤១% |
| អនុបាតឥណទានលុបចេញពីបញ្ជី (ដុល្លារអាមេរិក) | - | - |

## សង្ខេបទិន្នន័យ ២០២៥

សំពៀតឥណទានជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់
**៤៩១.០១៧** (ដុល្លារអាមេរិក)

ហានិភ័យឥណទានធំជាង ៣០ថ្ងៃ
**២០,៧៨** (%)

ទំហំឥណទានជាមធ្យម
**១១.៨១៣** (ដុល្លារអាមេរិក)

សំពៀតឥណទានសរុប
**១៤.៨៧៥.៧៤៣**

# លទ្ធផលសង្ខេបផ្នែកធនធានមនុស្ស

ផ្អែកទៅលើទិដ្ឋភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅឆ្នាំ២០២៥ នេះ ដែលមិនទាន់មានភាពល្អប្រសើរឡើងពេញលេញ បន្ទាប់ពីរងផលប៉ះពាល់ពីវិបត្តិសកលបណ្ដាលមកពីសង្គ្រាម និងបញ្ហាសេដ្ឋកិច្ចអន្តរជាតិ បានបង្កឱ្យមានផលប៉ះពាល់មួយផ្នែកដល់វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

ទោះបីស្ថិតក្នុងស្ថានភាពប្រឈមនានាក៏ដោយ ថ្នាក់ដឹកនាំរបស់ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅតែបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់បុគ្គលិកឱ្យកាន់តែមានវឌ្ឍនភាព។

ស្របតាមផែនការអាជីវកម្មរយៈពេលវែង ស្ថាប័នបានផ្តោតសំខាន់លើការជ្រើសរើសបុគ្គលិកដែលមានជំនាញ សុចរិតភាព និងសមត្ថភាពខ្ពស់ ព្រមទាំងជំរុញ និងលើកទឹកចិត្តឱ្យបុគ្គលិកទទួលបានឱកាសចូលរួមវគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅស្ថាប័ន ដើម្បីពង្រឹងសមត្ថភាព និងអភិវឌ្ឍជំនាញរបស់ពួកគេ ឱ្យស្របតាមចក្ខុវិស័យ និងយុទ្ធសាស្ត្រអភិវឌ្ឍរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងការសម្រេចបានជោគជ័យស្របតាមគោលបំណងរបស់ភាគទុនិក។

កត្តាទាំងនេះបានរួមចំណែកឱ្យស្ថាប័នអាចរក្សាបាននូវ ធនធាន មនុស្សមានគុណភាព និងបន្តជ្រើសរើសបុគ្គលិកថ្មីៗបន្ថែមស្របតាមតម្រូវការនៃផែនការអាជីវកម្ម។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ស្ថិតិបុគ្គលិករបស់គ្រឹះស្ថាន ហ្វូតាបា មានចំនួនសរុប ៩៥ នាក់ (បុរស ៦៨ នាក់ និងស្ត្រី ២៧ នាក់) ដែលមានការថយចុះចំនួន ០២ នាក់ ប្រៀបធៀបនឹងឆ្នាំ២០២៤។ ខាងក្រោមនេះជាទិន្នន័យសង្ខេបអំពីបុគ្គលិករបស់ ហ្វូតាបា៖




## បម្រែបម្រួលបុគ្គលិកពេញមួយឆ្នាំ
(ឆ្នាំ ២០២៥)



## ចំនួនបុគ្គលិកសរុប






# អំពី ហ្វូតាបា

- ផែនទីតំបន់ប្រតិបត្តិការ
- ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា
- ប្រវត្តិសង្ខេបរបស់ ហ្វូតាបា
- ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល
- ស្លាកសញ្ញារបស់ ហ្វូតាបា

# ផែនទីតំបន់ប្រតិបត្តិការ




**១២** ចំនួនខេត្តប្រតិបត្តិ

**៦០** ចំនួនស្រុកប្រតិបត្តិ

**២២៩** ចំនួនឃុំប្រតិបត្តិ

**៦១៤** ចំនួនភូមិប្រតិបត្តិ

## ១ ការិយាល័យកណ្តាល និងសាខាការិយាល័យកណ្តាល

ផ្ទះលេខ៤៧ មហាវិថីយោធពលខេមរភូមិន្ទ ភូមិ១ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ.

០៧០ ៣៥៨ ៣៣៣

## ២ សាខាខណ្ឌព្រែកព្នៅ

#១៨A-B ផ្លូវលេខ៥ ភូមិដួង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

០៧០ ៣៥៧ ៣៣៣

## ៣ សាខាខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ៧៨ក-ខ ផ្លូវជាតិលេខ៤ ភូមិព្រៃស្វាយ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

០៧០ ៣៥៩ ៣៣៣

## ៤ សាខាក្រុងច្បារមន

ផ្លូវជាតិលេខ៤ ភូមិក្រាំងពលទេព សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

០៧០ ៣១៤ ៣៣៣

## ៥ សាខាក្រុងដូនកែវ

ភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ

០៧០ ៩៦៤ ៣៣៣

# ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា

តាំងពីចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននាចុងឆ្នាំ២០១៥ កន្លងមក គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ពីធនាគារជាតិនៃកម្ពុជា ក្រោមបេសកកម្ម និងទស្សនៈវិស័យដ៏ច្បាស់លាស់របស់ខ្លួន ដែលចង់ក្លាយខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅក្នុងប្រទេសកម្ពុជាផងដែរ។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតបន្តសុពលភាពអាជ្ញាបណ្ណជូនគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី រយៈពេល ៣ឆ្នាំបន្ថែមទៀត  ក្រោយមកដោយមើលឃើញពីប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទាន  និងបានកែសម្រួលលើចំណុចខ្វះខាតតាមអនុសាសន៍នៃការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍ប្រកបអាជីវកម្មជាផ្លូវការជូនគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ ហើយធនាគារជាតិនៃកម្ពុជាក៏បានចេញសន្លឹកអាជ្ញាបណ្ណថ្មីជាមួយនិងទេសាភិបាលថ្មី នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ ព្រមទាំងនៅក្នុងឆ្នាំ២០២៥ គ្រឹះស្ថាន បានធ្វើការផ្លាស់ប្តូរទីតាំងការិយាល័យកណ្តាលថ្មីរបស់ខ្លួន ដែលបានចេញសន្លឹកអាជ្ញាបណ្ណថ្មីពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥។ ចាប់តាំងពីឆ្នាំ២០១៦ ក្រុមហ៊ុន AZUMA & CO., LTD. ( ជាក្រុមហ៊ុនជប៉ុន ) ក៏បានក្លាយជាភាគទុនិកកាន់កាប់ភាគហ៊ុន ១០០% របស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី រហូតមកដល់បច្ចុប្បន្ននេះ។

បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ យើងមានបុគ្គលិកសរុបចំនួន ៩៥នាក់ ស្រ្តីចំនួន ២៧នាក់ និងបុរសចំនួន ៦៨នាក់ ដែលបាននឹងកំពុងបម្រើការងារនៅការិយាល័យកណ្តាល  និងសាខាចំនួន  ០៥  ខេត្ត-រាជធានីរួមមាន  ការិយាល័យកណ្តាល  (សាខាការិយាល័យកណ្តាល ) សាខាខណ្ឌព្រែកព្នៅ សាខាខណ្ឌពោធិ៍សែនជ័យ សាខាក្រុងច្បារមន និងសាខាក្រុងដូនកែវ  ចំពោះអតិថិជនដែលបាន និងកំពុងទទួលកម្ចីមានសរុប  ១.២៤៧នាក់  ជាមួយនឹងផលបត្រឥណទានសរុប  ១៤.៧៣០.៥១២  ដុល្លារអាមេរិក  ក្រោមការគ្រប់គ្រងដោយមន្រ្តីឥណទានចំនួន  ៣០នាក់  ដែលលទ្ធផលជារួមមានការកើនឡើងតិចតួចលើចំនួនអតិថិជន  តែថយចុះបន្តិចលើផលបត្រឥណទានបើប្រៀបធៀបនឹងឆ្នាំមុន តែគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅតែអាចគ្រប់គ្រងស្ថានភាព និងបន្តដំណើររបស់ខ្លួនប្រកបដោយវិជ្ជមានទៅថ្ងៃអនាគត។ ចំពោះការគ្រប់គ្រងលើគុណភាពឥណទាន ក្នុងអំឡុង ៤ឆ្នាំកន្លងមកពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ យើងបានរក្សាកម្រិតហានិភ័យនៃផលបត្រឥណទានក្នុងអត្រា ០.៤៦% និងអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រា 0% ដែលនេះជាលទ្ធផលមួយដ៏ល្អប្រសើរលើការគ្រប់គ្រងឥណទានដែលយើងបានបញ្ចេញនៅក្នុងឆ្នាំនីមួយៗ  ដោយឡែកចាប់តាំងពីឆ្នាំ ២០២០ កន្លងមកមានការកើនឡើងនូវបំណុលយឺតយ៉ាវជាបន្តបន្ទាប់ ជាក់ស្តែងក្នុងឆ្នាំ២០២៥ មានកម្រិតហានិភ័យនៃផលបត្រឥណទានក្នុងអត្រា ២០,៧៨% ហើយអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រា 0% ដោយសារតែមានបញ្ហាសង្រ្គាមរវាងប្រទេសក្នុងតំបន់មួយចំនួន  សង្រ្គាមរវាងសហរដ្ឋអាមេរិកនឹង  ប្រទេសអ៊ីរ៉ង់  ហើយចុងក្រោយនេះសង្រ្គាមឈ្លានពានព្រំដែនពីប្រទេសថៃមកលើប្រទេសកម្ពុជា ដែលនាំឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចស្ទើរតែគ្រប់ប្រទេសនៅលើពិភពលោក និងកម្ពុជាផងដែរ។ ក្នុងស្ថានភាពនេះផងដែរ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បាននឹងកំពុងផ្តល់ឥណទានរៀបចំឡើងវិញជូនចំពោះអតិថិជនមួយចំនួនគិតត្រឹមបំណាច់ឆ្នាំ២០២៥ ដែលមានចំនួន ១៦,៣% ស្របទៅតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជាដែលនៅតែបន្តអនុវត្ត និងវិធានការជួយសម្រាលបន្ទុកដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជម្លោះព្រំដែនដែលបណ្តាលមកពីការឈ្លានពានពីប្រទេសថៃ ដែលនឹងត្រូវបញ្ចប់ក្នុងខែឧសភា ឆ្នាំ២០២៦។

ចំពោះស្ថានភាពរបាយការណ៍ហិរញ្ញវត្ថុវិញ យើងឃើញថា គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានចំណាយពេលវេលាជាង ១ឆ្នាំទើបទទួលបានការចំណេញសុទ្ធរបស់ខ្លួនចាប់តាំងពីឆ្នាំ២០១៧ រហូតមក ហើយទោះបីមានផលប៉ះពាល់ពីកត្តាជាច្រើនមកយ៉ាងណាក៏ដោយ ក៏ការចំណេញសុទ្ធនៅបំណាច់ឆ្នាំ២០២៥ នេះមានចំនួន ២៣២.១២៥ ដុល្លារអាមេរិក (មានការធ្លាក់ចុះជាងឆ្នាំ២០២៤) ជាមួយនឹងទ្រព្យសកម្មចំនួន ១៥.៨៨៦.៦៤៥ ដុល្លារអាមេរិក (មានការកើនឡើងជាងឆ្នាំ២០២៤) ជាលទ្ធផលហិរញ្ញវត្ថុមួយមិនទាន់ល្អប្រសើរនៅឡើយបើធៀបទៅនឹងផែនការដែលបានកំណត់ក្នុងស្ថានភាពដែលលំបាកដែលមានប្រឈមនឹងវិបត្តិនានាជាបន្តបន្ទាប់  តែគ្រឹះស្ថាននៅតែបន្តប្រតិបត្តិការសកម្មភាពអាជីវកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងព្យាយាមដោះស្រាយបញ្ហានានា និងការខិតខំប្រឹងប្រែងជំនះនូវឧបសគ្គទាំងឡាយជាពិសេសការទប់ស្កាត់ការកើនឡើងនូវឥណទានយឺតយ៉ាវ និងការដោះស្រាយឱ្យបានទាន់ពេលវេលា។

ស្របទៅនឹងទីផ្សារប្រកួតប្រជែងលើផលិតផល  និងសេវាកម្មនៅក្នុងឆ្នាំ២០២៥ គ្រឹះស្ថានបានបង្កើតនូវផលិតផលឥណទានយានយន្ត និងបរិក្ខារប្រើប្រាស់ថ្មី  ដើម្បីជាចំណែកទីផ្សារមួយបន្ថែមទៀតដោយស្របនឹងតម្រូវការរបស់អតិថិជនបច្ចុប្បន្ន  ហើយជាផ្នែកមួយក្នុងការបន្តការគាំទ្រដល់ការអភិវឌ្ឍលើការអប់រំ និងជីវភាពរបស់បុគ្គលិក គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី  ក៏នៅតែផ្តល់ឥណទានក្នុងអត្រាការប្រាក់ទាបបំផុតលើឥណទានសិក្សា និងឥណទានបុគ្គលិក ដែលជាគោលដៅចម្បងរបស់ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគទុនិកស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីភាពវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី  នឹងបន្តអនុវត្តផែនការគោល ផែនការរំកិលប្រចាំឆ្នាំ និងផែនការយុទ្ធសាស្រ្តរយៈពេលវែងរបស់ខ្លួន ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារឱ្យបានទូលំទូលាយ និងឆ្លើយតបទៅនឹងកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់នៅលើទីតាំងប្រតិបត្តិការរបស់គ្រឹះស្ថានដែលមានស្រាប់ និងការរីកចម្រើនរបស់ប្រទេសនាពេលបច្ចុប្បន្ន និងអនាគត។

# ប្រវត្តិសង្ខេបរបស់គ្រឹះស្ថាន ហ្វូតាបា

គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ត្រូវបានបង្កើតឡើងស្របតាមគោលបំណង និងក្តីសុបិនរបស់ភាគទុនិកតាមរយៈគំនិតផ្តួចផ្តើម ព្រមទាំងការប្តេជ្ញាចិត្តខ្ពស់ ភាគទុនិកបានជម្នះនូវរាល់ឧបសគ្គទាំងឡាយរហូតទទួលបានអាជ្ញាបណ្ណជាផ្លូវការពីធនាគារជាតិនៃកម្ពុជា លេខ ម.ហ-៦៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ហើយធនាគារជាតិនៃកម្ពុជាក៏បានចេញសន្លឹកអាជ្ញាបណ្ណថ្មីជាមួយនឹងទេសាភិបាលថ្មី ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤។ នៅក្នុងឆ្នាំ២០២៥ គ្រឹះស្ថាន បានធ្វើការផ្លាស់ប្តូរទីតាំងការិយាល័យកណ្តាលថ្មីរបស់ខ្លួន ដែលបានចេញសន្លឹកអាជ្ញាបណ្ណថ្មីពីធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥។

នៅដើមឆ្នាំ២០១៦ គ្រឹះស្ថានក៏ចាប់ផ្តើមប្រតិបត្តិការអាជីវកម្មជាមួយនឹងដើមទុនដំបូងរបស់ខ្លួនចំនួន ១.000.000 ដុល្លារអាមេរិក ដោយទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនជាច្រើន ដែលបង្ហាញពីភាពជោគជ័យដ៏ត្រចះត្រចង់។ ជាមួយគ្នានោះ ក្នុងឆ្នាំ២០១៦ ក្រុមហ៊ុន AZUMA & CO., LTD. ក៏បានក្លាយជាភាគទុនិកថ្មីរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ ក្រុមហ៊ុន AZUMA & CO., LTD. ជាក្រុមហ៊ុនជប៉ុន ដែលមានគោលគំនិតស្របគ្នាក្នុងការគាំទ្រលើកស្ទួយកម្រិតជីវភាពស្តង់ដាររស់នៅជូនដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មី តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។

ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នឹងបន្តអនុវត្តផែនការគោលរបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវវត្ថុបំណងនៃក្តីសុបិនរបស់ភាគទុនិក។ ជាក់ស្តែងគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតការិយាល័យសាខាថ្មីចំនួនបី (៣) បន្ថែមទៀតនៅចុងឆ្នាំ២០១៦ ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារទូលំទូលាយ និងឆ្លើយតបទៅតាមកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់។

សាខាបើកថ្មីទាំងបី (៣) នោះ ត្រូវបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦។ ដោយមើលឃើញពីដំណើរការជាវិជ្ជមាននៃការប្រតិបត្តិ និងការគ្រប់គ្រង ព្រមទាំងផែនការយុទ្ធសាស្រ្តវែងឆ្ងាយទៅថ្ងៃអនាគតរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានផ្តល់សុពលភាពអាជ្ញាបណ្ណរយៈពេល ៣ឆ្នាំបន្ថែមទៀត ហើយក្រោយមកធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍ប្រកបអាជីវកម្មជាផ្លូវការជូនគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។ ហើយក្នុងឆ្នាំ២០២៣ គ្រឹះស្ថានបានខិតខំប្រឹងប្រែងពង្រីកប្រតិបត្តិការសាខារបស់ខ្លួនមួយទៀតនៅក្នុងខេត្តតាកែវ (សាខាក្រុងដូនកែវ) ឱ្យស្របទៅតាមផែនការយុទ្ធសាស្រ្តរយៈពេលវែងរបស់ខ្លួន។ ហើយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានប្រតិបត្តិការអាជីវកម្មរបស់ខ្លួនមានរយៈពេល ១០ឆ្នាំមកហើយ ដែលមានទីតាំងកំពុងបម្រើសេវាអតិថិជនចំនួន ០៥ ខេត្ត/រាជធានីរួមមាន ការិយាល័យកណ្តាល (សាខាការិយាល័យកណ្តាល) សាខាខណ្ឌព្រែកព្នៅ សាខាខណ្ឌពោធិ៍សែនជ័យ សាខាក្រុងច្បារមន (ខេត្តកំពង់ស្ពឺ) និងសាខាក្រុងដូនកែវ (ខេត្តតាកែវ)។ ហើយនៅក្នុងឆ្នាំ២០២៥ នេះ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក៏បានផ្លាស់ប្តូរទីតាំងការិយាល័យកណ្តាលថ្មី និងការកែប្រែព័ត៌មានកម្រិតសាខាមួយចំនួនដូចជា ផ្លាស់ប្តូរនាយកសាខា កែសម្រួលនាមករណ៍សាខា និងកែសម្រួលអាសយដ្ឋាន។

ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥
ដើមទុនដំបូងចំនួន **១.០០០.០០០** ដុល្លារអាមេរិក




ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦
បន្ថែមដើមទុនចំនួន
១.០០០.០០០ ដុល្លារអាមេរិក

ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦
បន្ថែមដើមទុនចំនួន ៥.០០០.០០០ ដុល្លារអាមេរិក

## ការវិវឌ្ឍន៍នៃដើមទុន




| ២០១៥ | ២០១៦ | ២០១៧ | បច្ចុប្បន្ន |
|---|---|---|---|
| ១.០០០.០០០ ដុល្លារអាមេរិក | ២.០០០.០០០ ដុល្លារអាមេរិក | ៧.០០០.០០០ ដុល្លារអាមេរិក | ៧.០០០.០០០ ដុល្លារអាមេរិក |

# ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល

## ទស្សនៈវិស័យ និងបេសកកម្ម

### ទស្សនៈវិស័យ

ជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា ដែលលើកស្ទួយឲ្យល្អប្រសើរនូវកម្រិតជីវភាពរស់នៅរបស់អតិថិជននាពេលបច្ចុប្បន្ន និង អ្នកជំនាន់ថ្មី។

### បេសកកម្ម

ផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលទុកចិត្តបំផុត ទៅកាន់ សហគ្រាស ខ្នាតមធ្យម ខ្នាតតូច ខ្នាតតូចបំផុត និងរូបវន្តបុគ្គល ដោយបង្កើតនូវទីផ្សារដែលមានស្ថិរភាព ដើម្បីគាំទ្រទាំងអតិថិជននាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី ព្រមទាំងចូលរួមក្នុងសកម្មភាពសង្គម ដើម្បីសម្រេចនូវគោលបំណង ឬ ក្តីសុបិនរបស់ពួកគាត់ជាមួយអនាគតដ៏ប្រសើរ។

## តម្លៃស្នូល

- ០១ សុចរិតភាព
- ០២ មនុស្សជាតិ
- ០៣ ការតម្រង់ទិស
- ០៤ ការប្រកួតប្រជែង
- ០៥ សេចក្តីភ្លៀវភ្លា

# ស្លាកសញ្ញារបស់ ហ្វូតាបា

## និមិត្តសញ្ញា និងអត្ថន័យ

និមិត្តសញ្ញាសម្គាល់នេះ គឺសំដៅលើត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចមួយ ដែលបែកពន្លកចេញពីស្រទាប់ដី។

ត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចនេះ អាចលូតលាស់ជាឈើដ៏ធំមួយដើមនាពេលអនាគត ដ៏ឆាប់រហ័ស គឺអាស្រ័យលើការខិតខំបីបាច់ថែទាំ និងដាក់ជីយ៉ាងល្អិតល្អន់របស់យើងទាំងអស់គ្នា។
ក្នុងន័យនេះ យើងខ្ញុំជាគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី ប្រៀបបានទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុដ៏តូចមួយ ដែលទើបតែចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនលើវិស័យហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ហើយយើងខ្ញុំអាចអភិវឌ្ឍជាធនាគារឈានមុខមួយ ក្នុងព្រះរាជាណាចក្រកម្ពុជានាពេលអនាគតខាងមុខ ដើម្បីផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាពខ្ពស់ ធានាឲ្យបាននូវស្ថិរភាព និងផ្តល់អនាគតដ៏ត្រចះត្រចង់ បម្រើជូនសាធារណៈជនទាំងអស់របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី ឬ ក៏ធនាគារ **ហ្វូតាបា** ប្រៀបដូចជាត្រួយនៃពន្លកធញ្ញជាតិដ៏តូចរីកលូតលាស់ទៅជាដើមឈើដ៏ធំនាពេលអនាគតដ៏ខ្លីខាងមុខ។

គ្រឹះស្ថានយើងខ្ញុំអាចអភិវឌ្ឍឆាប់រហ័សប្រៀបដូចនឹងដើមឈើដ៏ធំ គឺអាស្រ័យលើបុគ្គលិកគ្រប់លំដាប់ថ្នាក់នីមួយៗនៃគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី មានកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ផងដែរ ហើយក៏ពឹងផ្អែកលើទំហំទុន ដែលគ្រឹះស្ថានទទួលបានពីភាគទុនិករបស់ខ្លួន ដើម្បីបម្រើសេចក្តីត្រូវការរបស់អតិថិជនយើងខ្ញុំ។

## ពណ៌

ពណ៌បៃតងនៃត្រួយពន្លកគ្រាប់ធញ្ញជាតិ គឺសំដៅភាពយកចិត្តទុកដាក់លើបរិស្ថានភាព សុខុដុម រវាងកំណើនសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាននាពេលបច្ចុប្បន្ន និង តទៅអនាគតសម្រាប់ជំនាន់ក្រោយ។

## ពាក្យស្លោក

**សុបិនក្លាយជាការពិត**

# អភិបាលកិច្ច

- ម្ចាស់ភាគទុនិក និងដើមទុន
- របនាសម្ព័ន្ធ
- ក្រុមប្រឹក្សាភិបាល
- គណៈគ្រប់គ្រង

# ម្ចាស់ភាគទុនិក និងដើមទុន




AZUMA & Co.,Ltd. ជាភាគទុនិកឯកកម្មសិទ្ធិកាន់កាប់លើភាគហ៊ុន ១០០ភាគរយ របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមសម្តែងនូវសុច្ឆន្ទៈ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋកម្ពុជា។

AZUMA & Co.,Ltd. ជាសហគ្រាសជប៉ុនសុទ្ធសាធ ដែលរូបខ្ញុំ Yosuke SASAKI ជាជនជាតិជប៉ុន ទទួលកាន់កាប់លើភាគហ៊ុន ១០០ ភាគរយ និងមានតួនាទីជាប្រធាននាយក នៃសហគ្រាស AZUMA & Co.,Ltd.

យើងខ្ញុំមានកិត្តិយសក្រៃលែង ក្នុងនាមជានីតិបុគ្គលនៃសហគ្រាស AZUMA & Co.,Ltd. ដែលបានចូលរួមចំណែកក្នុងនាមជាអ្នកផ្តល់ហិរញ្ញប្បទាន និងថែរក្សាអ្នកជំនាន់ក្រោយក៏ដូចជា ជួយលើកកម្ពស់កម្រិតស្តង់ដារ ការរស់នៅរបស់ពលរដ្ឋកម្ពុជាឲ្យកាន់តែប្រសើរឡើងៗ នៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែក លើគោលការណ៍ តម្លាភាព ប្រសិទ្ធភាព និងការផ្តល់សេវាហិរញ្ញប្បទាន ប្រកបដោយនិរន្តរភាព យូរអង្វែងរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី យើងខ្ញុំ។



# រចនាសម្ព័ន្ធ



ម្ចាស់ភាគហ៊ុនិក
ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការសវនកម្ម
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម
នាយកប្រតិបត្តិ
នាយករងប្រតិបត្តិ
គណៈកម្មការបង្កើតផលិតផល និងសេវាកម្មថ្មី
គណៈកម្មការឥណទាន
គណៈកម្មការប្រឹក្សានិយ័យ
គណៈកម្មការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា
គណៈកម្មការដឹកនាំអនុវត្តព័ត៌មានវិទ្យា
គណៈកម្មការយុទ្ធសាស្ត្រព័ត៌មានវិទ្យា
នាយកដ្ឋានទីផ្សារ
នាយកដ្ឋានប្រតិបត្តិការ
នាយកដ្ឋានហិរញ្ញវត្ថុ នាយិកា នាយកដ្ឋាន
នាយកដ្ឋានឥណទាន នាយក នាយកដ្ឋាន
នាយកដ្ឋានព័ត៌មានវិទ្យា នាយក នាយកដ្ឋាន
នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល
នាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម នាយក នាយកដ្ឋាន
នាយិការង នាយកដ្ឋានទីផ្សារ
នាយករង នាយកដ្ឋានប្រតិបត្តិការ
នាយករង នាយកដ្ឋានឥណទាន
នាយករង នាយកដ្ឋានព័ត៌មានវិទ្យា
នាយិការង នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល
ប្រធានផ្នែកសវនកម្មផ្ទៃក្នុង
ប្រធានផ្នែកហិរញ្ញវត្ថុ
ប្រធានផ្នែកដោះស្រាយបំណុល និងវិភាគឥណទាន
មន្ត្រីប្រតិបត្តិការជាន់ខ្ពស់ ៣ នាក់
គណនេយ្យករជាន់ខ្ពស់
មន្ត្រីគាំទ្រឥណទានជាន់ខ្ពស់
មន្ត្រីព័ត៌មានវិទ្យាជាន់ខ្ពស់ ២ នាក់
មន្ត្រីធនធានមនុស្ស និងរដ្ឋបាលជាន់ខ្ពស់
មន្ត្រីហ្វឹកហ្វឺន និងជ្រើសរើសបុគ្គលិកជាន់ខ្ពស់
មន្ត្រីច្បាប់ និងប្រតិបត្តិតាមជាន់ខ្ពស់
មន្ត្រីសវនកម្មផ្ទៃក្នុង
មន្ត្រីឌីហ្សាញ
មន្ត្រីបម្រើសេវាអតិថិជន
គណនេយ្យករ
សាខាការិយាល័យកណ្តាល នាយកសាខា
សាខាខណ្ឌព្រែកព្នៅ នាយកសាខា
សាខាខណ្ឌពោធិ៍សែនជ័យ នាយកសាខា
សាខាក្រុងច្បារមន នាយកសាខា
សាខាក្រុងដូនកែវ នាយកសាខា

# ក្រុមប្រឹក្សាភិបាល



**លោក ច្រឹក ផល្លី**
ប្រធានក្រុមប្រឹក្សាភិបាល

លោក **ច្រឹក ផល្លី** កើតនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៨១ សញ្ជាតិខ្មែរ បាន ចាប់ផ្តើមការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៥ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាល ក្រោយមកលោកត្រូវបានតែងតាំង និងទទួលស្គាល់ជាប្រធានក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ រហូតមកដល់ពេលបច្ចុប្បន្ន។ លោកមានបទពិសោធន៍ជាង ២០ឆ្នាំ ខាង ផ្នែកគ្រប់គ្រង ដែលក្នុងរយៈពេល ៥ឆ្នាំ លោកបានបំពេញតួនាទីជាប្រធានគ្រប់គ្រងផ្នែកទីផ្សារនៅក្រុមហ៊ុន Futaba Co., Ltd ក្នុងឆ្នាំ ២០០៧ លោកត្រូវបានតែងតាំងជានាយកចាត់ការទូទៅ ហើយបានបម្រើការងាររហូតមកដល់បច្ចុប្បន្ននេះ។ លោកបានបញ្ចប់ការ សិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យន័រតុន។



**លោក ជូនីជី សាសាគី**
សមាជិកក្រុមប្រឹក្សាភិបាល

លោក **ជូនីជី សាសាគី** កើតនៅទីក្រុង KANAGAWA ប្រទេសជប៉ុន ឆ្នាំ១៩៤៩ សញ្ជាតិជប៉ុន ត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សា ភិបាលដំបូងនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ និងទទួលស្គាល់ជាថ្មី នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៤ ពីធនាគារជាតិនៃកម្ពុជា។ លោក ជូនីជី សាសាគី បានបញ្ចប់ការសិក្សា ពីសាកលវិទ្យាល័យតូក្យូ នៅឆ្នាំ១៩៧៥ បច្ចុប្បន្ន ជាប្រធាន និងជាភាគទុនិក ១០០% នៃ ក្រុមហ៊ុន FutureBud International Co., Ltd នៅទីក្រុងតូក្យូនៃប្រទេសជប៉ុន។



**លោក ង៉ែត សុវណ្ណារ៉ូ**
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក **ង៉ែត សុវណ្ណារ៉ូ** មានសញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៥៩ ក្នុងខេត្តតាកែវ នៃប្រទេសកម្ពុជា។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកកសិកម្ម ពីសាកលវិទ្យាល័យ មិត្តភាពនៃប្រជាជនម៉ូស្គូ នៃអាហារូបករណ៍ ផ្នែកអនុបណ្ឌិត ផ្តល់ដោយរដ្ឋាភិបាលរុស្ស៊ី ក្នុងឆ្នាំ១៩៨៧។ លោកមានបទពិសោធន៍ ច្រើនជាង ២៥ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩២ ក្នុងមុខតំណែងប្រធានគណនេយ្យ និងរយៈពេល ៨ឆ្នាំ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន នៃ ក្រសួងផែនការ។



**លោក ហ៊ាន សុខុម**
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក **ហ៊ាន សុខុម** ជាជនជាតិខ្មែរ កើតនៅឆ្នាំ១៩៥៧ នៅក្នុងខេត្តក្រចេះ ប្រទេសកម្ពុជា។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ កាលពីថ្ងៃ ទី០៨ ខែកក្កដា ឆ្នាំ២០២៤។ លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតទស្សនវិជ្ជាផ្នែកនិរុត្តិវិទ្យា នៅវិទ្យាស្ថានបូព៌ាសាស្ត្រនៃបណ្ឌិត្យសភាវិទ្យាសាស្ត្រសហព័ន្ធរុស្ស៊ីក្នុងឆ្នាំ ១៩៩២ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនិរុត្តិវិទ្យា នៅសាកលវិទ្យាល័យមិត្តភាពប្រជាជាតិប៉ាទ្រីសលូមុំបាក្នុងឆ្នាំ១៩៨៦ នៅទីក្រុងម៉ូស្គូ នៃប្រទេសរុស្ស៊ី។ លោកមានបទពិសោធន៍ ១៦ឆ្នាំ ចាប់តាំង ពីឆ្នាំ ២000-២០១៦ នៅក្នុងមជ្ឈមណ្ឌលសម្រាប់ការសិក្សាខ្ពស់ជាអង្គការស្រាវជ្រាវមិនរកប្រាក់ចំណេញ និងតួនាទីគ្រប់គ្រងទូទៅនៃស្ថាប័ននោះ ព្រមទាំងជាអ្នកសម្របសម្រួលស្រាវជ្រាវ នៃគម្រោងស្រាវជ្រាវទៅលើការស្ទង់មតិសាធារណៈ ការស្ទង់មតិអំពីឥរិយាបថសង្គម ក៏ដូចជាប្រភេទនៃការសិក្សាបែបគុណវិស័យ និងបរិមាណវិស័យដែលរៀបចំដោយម្ចាស់ជំនួយអន្តរជាតិ និង១៩ឆ្នាំ ជាអ្នកដឹកនាំនៃអង្គការមួយដែលផ្តោតជាសំខាន់លើការអភិវឌ្ឍ ការគ្រប់គ្រងផ្នែក្នុងការគ្រប់គ្រងថវិកា ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ រក្សាការអនុលោមភាពគោលនយោបាយគណនេយ្យ/ច្បាប់ និងបទប្បញ្ញត្តិ នៃពន្ធដារជាដើម និងធ្វើការយ៉ាងជិតស្និតជាមួយសវនករឯករាជ្យ។



**លោក អ៊ុំ ពិសិដ្ឋ**
នាយកប្រតិបត្តិ

លោក **អ៊ុំ ពិសិដ្ឋ** បានចាប់ផ្ដើមអាជីពការងាររបស់លោក ជាមួយគ្រឹះស្ថាន **ហ្វូតាបា** នៅចុងឆ្នាំ ២០១៥ ក្នុងតួនាទីជានាយក នាយកដ្ឋានឥណទាន បន្ទាប់មកនៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងជាជំនួយការនាយកប្រតិបត្តិ ដែលត្រូវទទួលបន្ទុកគ្រប់គ្រង និងមើលការខុសត្រូវលើនាយកដ្ឋានចំនួនបី គឺនាយកដ្ឋានឥណទាន នាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានទីផ្សារ។ លោកបានបញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាបត្រផ្នែកគ្រប់គ្រងទូទៅ នៅសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទទួលបានសញ្ញាបត្រភាសាអង់គ្លេសថ្នាក់ IEAP ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយបានចូលរួមវគ្គបណ្ដុះបណ្ដាលសន្និសិទ និងសិក្ខាសិលាជាច្រើនដែលទាក់ទងទៅនឹងការវិវឌ្ឍន៍វិស័យអចលនទ្រព្យ ការគ្រប់គ្រងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ ចំពោះបទពិសោធន៍ការងារ លោកបានចំណាយពេលជាង ១៩ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាមួយនិងមុខតំណែងជាច្រើនដូចជា មន្ត្រីសាខា នាយកសាខា នាយកគ្រប់គ្រងតំបន់ នាយក នាយកដ្ឋានប្រតិបត្តិការ នាយក នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង នាយកគ្រប់គ្រងឥណទាន នាយក នាយកដ្ឋានឥណទាន។ លោកក៏បានចំណាយ ពេលជាង ៣ឆ្នាំ បម្រើការងារនៅវិស័យទូរគមនាគមន៍ ផង ដែរ។ លោក អ៊ុំ ពិសិដ្ឋ ត្រូវបានតែងតាំងជា នាយកប្រតិបត្តិ ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ នេះតទៅ។



**លោក ព្រាប កណ្ដឹង**
នាយករងប្រតិបត្តិ

លោក **ព្រាប កណ្ដឹង** បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ (Master of Business Specializing in Finance) ពីសាកលវិទ្យាល័យ Charles Sturt University នៃប្រទេសអូស្ត្រាលី និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ លោកមានបទពិសោធន៍ការងារជាច្រើនឆ្នាំ ដែលពាក់ព័ន្ធទៅនឹង វិស័យធនាគារ និងហិរញ្ញវត្ថុ ការសិក្សាក៏ដូចជាបទពិសោធន៍ការងារបានធ្វើអោយគាត់មានការអភិវឌ្ឍ ជាបន្តបន្ទាប់នូវភាពរីកចម្រើននៃអាជីពការងាររបស់គាត់។ មុនពេលគាត់ចូលរួមបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** លោកមានបទពិសោធន៍ការងារជាច្រើនពាក់ពន្ធ័ទៅនឹងការគ្រប់គ្រងគណនេយ្យ ប្រឹក្សាយោបល់ផ្នែកគណនេយ្យ និងជានាយក នាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ។ លោកបានចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាបា** នៅឆ្នាំ២០១៥ ដែលមានតួនាទីជានាយក នាយកដ្ឋានហិរញ្ញវត្ថុ។ នៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងតួនាទីជាជំនួយការនាយកប្រតិបត្តិ ដែលទទួលខុសត្រូវទៅលើនាយកដ្ឋានចំនួនបី ដូចជា នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានព័ត៌មានវិទ្យា និង នាយកដ្ឋានធន ធានមនុស្ស និង រដ្ឋបាល។ លោក ព្រាប កណ្ដឹង ត្រូវបាន តែងតាំងជា នាយករងប្រតិបត្តិ ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ នេះតទៅ។



**លោក គង់ សារ៉ាត់**
នាយក នាយកដ្ឋានព័ត៌មានវិទ្យា

លោក **គង់ សារ៉ាត់** ជាជនជាតិខ្មែរ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងក្នុងឆ្នាំ២០១១ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា និងផ្នែកអក្សរសាស្ត្រអង់គ្លេសផងដែរ។ ជាមួយនិងអតីតភាពការងារ លោកមានតួនាទីជាប្រធានគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា នៃធនាគារពាណិជ្ជធំមួយនៅកម្ពុជា ដែលទទួលខុសត្រូវលើផ្នែកប្រព័ន្ធធនាគារស្នូលប្រព័ន្ធ Card និង SWIFT ជាមួយនិងមុខជំនាញបច្ចេកទេសជាច្រើនដូចជាការរៀបចំដំណើរការប្រព័ន្ធធនាគារ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្ដាញ Network ប្រកបដោយសុវត្ថិភាព និងការរៀបចំគោលនយោបាយគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា។ នៅដើមឆ្នាំ ២០១៦ គាត់បានចូលបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** ជានាយករងផ្នែកព័ត៌មានវិទ្យា ក្រោយមកបានរយៈពេល ៦ខែ បន្ទាប់ គាត់ត្រូវបានដំឡើងតួនាទីជានាយក នាយកដ្ឋានព័ត៌មានវិទ្យា។ គាត់ជាអ្នកចាប់ផ្ដើមដំបូងក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ Network រៀបចំមជ្ឈមណ្ឌលទិន្នន័យ មជ្ឈមណ្ឌលទិន្នន័យសង្គ្រោះបន្ទាន់ គោលនយោបាយគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា ក៏ដូចជាគោលនយោបាយសុវត្ថិភាពទិន្នន័យសម្រាប់គ្រឹះស្ថាន **ហ្វូតាបា** ចាប់តាំងពីការកកើតដំបូងនៃគ្រឹះស្ថាន។ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ គាត់មានបទពិសោធន៍ផ្នែកព័ត៌មានវិទ្យាជាង ១០ឆ្នាំ មកហើយ។



**លោក ស ភារុំ**
នាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម

លោក **ស ភារុំ** បានចូលបម្រើការងារក្នុងគ្រឹះស្ថាន **ហ្វូតាបា** ក្នុងតួនាទីជា នាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និង ប្រតិបត្តិតាម ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧។ មុនពេលគាត់ចូលបម្រើការងារនៅគ្រឹះស្ថាន **ហ្វូតាបា** លោកបានបម្រើការងារនៅគ្រឹះស្ថាន ចម្រើន ក្នុងតួនាទីចុងក្រោយជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនីតិកម្ម ហើយគាត់បានចាប់ផ្ដើមការងារក្នុងតួនាទីជាច្រើនជាមួយគ្រឹះស្ថាន ចម្រើន ដែលចាប់ផ្ដើមពីខែកុម្ភៈ ឆ្នាំ២០០៩ ជាមន្ត្រីឥណទាន និងក្លាយជាមន្ត្រីសវនកម្មផ្ទៃក្នុង ក្នុងខែកុម្ភៈ ឆ្នាំ ២០១០។ ក្រោយមក គាត់ត្រូវបានតែងតាំងជាប្រធានសាខា នៅខែវិច្ឆិកា ឆ្នាំ២០១០ និងប្ដូរទៅជាមន្ត្រីប្រតិបត្តិតាមជាន់ខ្ពស់ ក្នុងខែ មិថុនា ឆ្នាំ ២០១២។ បន្ទាប់មក គាត់ក៏ត្រូវបានដំឡើងទៅជាប្រធានផ្នែកច្បាប់ និងប្រតិបត្តិតាម ក្នុងខែមិថុនា ឆ្នាំ២០១៣ និងជាប្រធាននាយកដ្ឋានច្បាប់ ក្នុងខែមករា ឆ្នាំ២០១៥ ហើយបានទទួលខុសត្រូវក្នុងតួនាទីចុងក្រោយជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនីតិកម្ម។ ហើយគាត់ក៏ធ្លាប់បម្រើការងារនៅសណ្ឋាគារ Feeling Home ជាអ្នកទទួលភ្ញៀវ រយៈពេល ១ឆ្នាំ និងធ្វើការជាអ្នកស្ម័គ្រចិត្តជាមួយអង្គការទស្សនៈពិភពលោកនៅ ស្រុករយៈពេល ៤ឆ្នាំផងដែរ។ គាត់បានទទួល សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ផ្នែកនីតិឯកជន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាបត្រផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យធនធានមនុស្ស។ ក្នុងតួនាទី និងការទទួលខុសត្រូវនោះ គាត់មានបទពិសោធន៍ ក្នុងតួនាទីផ្សេងៗគ្នារយៈពេល ៩ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។



**លោក យ៉ាត ប៊ុនជា**
នាយក នាយកដ្ឋានឥណទាន

លោក **យ៉ាត ប៊ុនជា** បច្ចុប្បន្នបានចូលបម្រើការងារនៅគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី តួនាទីជានាយក នាយកដ្ឋានឥណទាន។ មុនចូលបម្រើការនៅគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី លោកធ្លាប់កាន់មុខតំណែងជាច្រើនក្នុងវិស័យហិរញ្ញវត្ថុ ដូចជា៖ មន្រ្តីឥណទាន មន្រ្តីឥណទានជាន់ខ្ពស់ នាយកផ្នែកឥណទាន នាយកសាខា នាយកសាខាខេត្ត នាយកប្រតិបត្តិការ និងជានាយកគ្រប់គ្រងទូទៅផងដែរ លោកមានជំនាញ និងបទពិសោធន៍ការងារជាមួយវិស័យ NGO និងមីក្រូហិរញ្ញវត្ថុអស់រយៈពេលជាង ២៥ឆ្នាំ។ លោកក៏ធ្លាប់ធ្វើការងារជាមួយអ៊ុនតាក់ (UNTAC) ក្នុងតួនាទីជាអ្នកបកប្រែ និងជាអ្នកសង្កេតការការបោះឆ្នោតក្នុងឆ្នាំ ១៩៩៣។ លោកធ្លាប់បំពេញការងារជាមន្ត្រីរាជការ ជាគ្រូវិទ្យាល័យមុខវិជ្ជាបង្រៀនជីវវិទ្យា និងភាសាអង់គ្លេស។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មឯកទេសគ្រប់គ្រងទូទៅ នៅសាកលវិទ្យាល័យបៀលប្រាយក្នុងឆ្នាំ២០០៩។ លោកបានចូលរួមវគ្គបណ្តុះបណ្តាល និងជំនាញវគ្គខ្លីៗជាច្រើនជាមួយសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា និងវគ្គបណ្តុះបណ្តាលពិសេសផ្សេងទៀតដូចជា៖ Credit Unions Management រៀបចំដោយ Asian Confederation of Credit Unions (ACCU) និង Credit Union League of Thailand Limited (CULT) នៅប្រទេសថៃ។



**អ្នកស្រី សេង គន្ធា**
នាយិកា នាយកដ្ឋានហិរញ្ញវត្ថុ

អ្នកស្រី **សេង គន្ធា** បានចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងឋានៈជានាយិកា នាយកដ្ឋានហិរញ្ញវត្ថុ ក្នុងឆ្នាំ ២០២៥។ មុនពេលចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាបា** លោកស្រីបានកាន់តំណែងសំខាន់ៗជាច្រើនក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ ដោយមានបទពិសោធន៏រីកចម្រើនជាង ១៤ ឆ្នាំ។ អ្នកស្រីបានចាប់ផ្តើមអាជីពជា បេឡាធិការ នៅ Kredit MFI ក្នុងឆ្នាំ២០១១ បន្ទាប់មកបានផ្លាស់ប្តូរទៅជាប្រធានបេឡាធិការនៅធនាគារប្រៃសណីយ៍កម្ពុជា ក្នុងឆ្នាំ២០១៣។ នៅឆ្នាំ២០១៦ អ្នកស្រីបានចូលរួមជាមួយ LED MFI ក្នុងឋានៈជាប្រធានផ្នែកគ្រប់គ្រងសាច់ប្រាក់ ហើយក្រោយមកត្រូវបានដំឡើងឋានៈជាប្រធានរតនាគារ និងជាប្រធានហិរញ្ញវត្ថុស្តីទីក្នុងឆ្នាំ២០២១។ អ្នកស្រីបានផ្លាស់ប្តូរឋានៈជាប្រធានហិរញ្ញវត្ថុនៅ GB MFI ក្នុងឆ្នាំ២០២២ ហើយបន្ទាប់មកបានផ្លាស់មកបម្រើការជានាយិកាហិរញ្ញវត្ថុ និងរតនាគារនៅ Chokchey MFI ក្នុងឆ្នាំ២០២៣។ អ្នកស្រី គន្ធា ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យ Build Bright (២០១២) ហើយបច្ចុប្បន្នកំពុងសិក្សាបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកធនាគារ និងហិរញ្ញវត្ថុនៅសាកលវិទ្យាល័យ Asia Europe។

# ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

- ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម
- សវនកម្មផ្ទៃក្នុង

# ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

## គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម (កម្រិតក្រុមប្រឹក្សាភិបាល)

គ្រឹះស្ថាន បានបង្កើតឱ្យមានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងកម្រិតក្រុមប្រឹក្សាភិបាលដែលមានសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យជាប្រធាន ហើយក៏បានធ្វើការកែសម្រួលលើកទី១ លើលក្ខខណ្ឌបំពេញការងាររបស់គណៈកម្មាធិការនេះកាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ ផងដែរ។ នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម ជាអ្នកសម្របសម្រួលដើម្បីពិភាក្សាអំពីរបាយការណ៍នៃការប្រតិបត្តិតាមជាមួយគ្រប់នាយកដ្ឋាន ឬគណៈគ្រប់គ្រង និងពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ និងភាពពេញលេញនៃការវិភាគហានិភ័យប្រតិបត្តិតាមដែលតម្រូវដោយច្បាប់ប្បញ្ញត្តិនានា។

រាល់ហានិភ័យប្រតិបត្តិតាមសំខាន់ៗត្រូវបានបង្ហាញ និងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ត្រឡប់មកវិញក្នុងការប្រតិបត្តិតាម និងដោះស្រាយឱ្យបានទាន់ពេលវេលា។ បន្ថែមលើនេះទៀត នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម ក៏ជាសមាជិកនៃគណៈកម្មការក្នុងកម្រិតគណៈគ្រប់គ្រង ដែលមានគណៈកម្មការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា គណៈកម្មការយុទ្ធសាស្ត្រព័ត៌មានវិទ្យា គណៈកម្មការដឹកនាំអនុវត្តព័ត៌មានវិទ្យា និងគណៈកម្មការអភិវឌ្ឍន៍ផលិតផល ដើម្បីត្រួតពិនិត្យ និងអនុវត្តឱ្យបានត្រឹមត្រូវលើផ្នែកព័ត៌មានវិទ្យា និងការបង្កើតថ្មី ឬកែលម្អផលិតផលឥណទាន និងសេវាកម្មនានា។

## ភារកិច្ច និងការទទួលខុសត្រូវ

- ពិនិត្យ និងធានាលើការបង្កើត និងកែប្រែនូវនីតិវិធី និងគោលការណ៍ក្នុងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ពិនិត្យ និងធានាលើការបង្កើត និងកែប្រែនូវនីតិវិធី និងគោលការណ៍ច្បាប់ និងប្រតិបត្តិតាម ក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ត្រួតពិនិត្យលើការធ្វើបច្ចុប្បន្នភាពជាប្រចាំនូវការវាយតម្លៃនៃមុខងារប្រតិបត្តិតាម ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិនានា។
- ពិនិត្យជាប្រចាំនូវបញ្ជីត្រួតពិនិត្យការប្រតិបត្តិតាមផ្ទៃក្នុង ដើម្បីកំណត់ពីហានិភ័យប្រតិបត្តិតាម និងចាត់វិធានការ និងផែនការសកម្មភាពបន្ត ក្នុងការគ្រប់គ្រងហានិភ័យឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។
- ពិចារណា និងពិនិត្យលើរបាយការណ៍សវនកម្មដែលបានរកឃើញពាក់ព័ន្ធផ្នែកប្រតិបត្តិតាម និងហានិភ័យផ្នែកច្បាប់ ដែលកំពុងកើតមានឡើង និងផលប៉ះពាល់នានា។
- ត្រួតពិនិត្យនៃការប្រតិបត្តិតាមប្រកបដោយប្រសិទ្ធភាពលើការអនុវត្តនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិនៃកម្ពុជា។
- ធានាថា ការបណ្តុះបណ្តាលចាំបាច់ត្រូវបានផ្តល់ជូនដល់គ្រប់បុគ្គលិក និងដើម្បីធានាឱ្យបាននូវការយល់ដឹងនៃសកម្មភាពប្រតិបត្តិតាម រួមទាំងការយល់ដឹងនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យក្នុងគ្រឹះស្ថាន។
- ពិនិត្យ និងយល់ព្រម និងផ្តល់យោបល់ដល់ការអនុវត្តលើការអនុម័តផែនការត្រួតពិនិត្យ រួមទាំងការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម យ៉ាងហោចណាស់មួយឆ្នាំម្តង។

## ការប្រជុំ និងសមាជិកភាព

គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិច ៣នាក់។ សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក ង៉ែត សុវណ្ណារ៉ូ | សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ | ប្រធាន |
| ២. លោក ដូនីជី សាសាគី | សមាជិកក្រុមប្រឹក្សាភិបាល | សមាជិក |
| ៣. លោក ស ភារុំ | នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម | សមាជិក/លេខាធិការ |

កិច្ចប្រជុំគណៈកម្មាធិការនេះត្រូវធ្វើឡើងយ៉ាងតិច ២ដងក្នុង១ឆ្នាំ ដែលមានការស្នើឡើងដោយប្រធាន ឬតាមសំណើរបស់សមាជិក។ ជាក់ស្តែងក្នុងឆ្នាំ២០២៥ កិច្ចប្រជុំគណៈកម្មាធិការនេះ បានប្រព្រឹត្តទៅបានចំនួន ២លើកគឺ លើកទី១ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៥ តាមរយៈការជួបប្រជុំផ្ទាល់ និងលើកទី២ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ តាមរយៈការជួបប្រជុំផ្ទាល់នៅការិយាល័យកណ្តាលរបស់គ្រឹះស្ថាន។

និយ័តករ ក្រុមហ៊ុនសវនកម្មឯករាជ្យ និងអ្នកពិគ្រោះយោបល់ ជាផ្នែកមួយនៃការត្រួតពិនិត្យលើប្រតិបត្តិការរបស់ស្ថាប័នពីខាងក្រៅ ដែលអាចបង្ហាញឱ្យឃើញថាគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានចំណុចខ្វះខាតកំណត់ហានិភ័យកើតឡើងនានា និងកំណត់ច្បាស់ពីតម្រូវការរបស់ស្ថាប័នដែលត្រូវកែលម្អ។ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម បានបន្តពង្រឹងការអនុវត្តផ្ទៃក្នុងរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ដោយផ្តោតលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានានៃការផ្តល់អាជ្ញាបណ្ណរបស់ធនាគារជាតិនៃកម្ពុជា និងការចុះបញ្ជីជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាបាននូវការពង្រីកអាជីវកម្ម និងប្រតិបត្តិការរបស់គ្រឹះស្ថានប្រកបដោយភាពត្រឹមត្រូវពេញលេញស្របតាមច្បាប់ បទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិនានានៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។

សមាជិកក្រុមប្រឹក្សាភិបាល បានសម្រេចបង្កើតឱ្យមាននាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម ដែលទទួលខុសត្រូវដោយនាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម គឺដើម្បីធានាថា ការគ្រប់គ្រងហានិភ័យដែលអាចកើតឡើង និងការប្រតិបត្តិតាមរបស់គ្រឹះស្ថាន ឱ្យមានភាពច្បាស់លាស់ដោយត្រូវត្រួតពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុងដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃលើហានិភ័យទាំងខាងក្នុង និងក្រៅដែលអាចមានការគំរាមកំហែង ឬផលប៉ះពាល់ដល់ប្រតិបត្តិការរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី និងធានាថាការអនុវត្ត និងនីតិវិធីត្រូវបានអនុវត្តបានពេញលេញស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា។ ក្រៅពីនេះលោកក៏ទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យការអនុលោមទៅតាមគោលការណ៍ផ្ទៃក្នុង នីតិវិធី និងគោលការណ៍ណែនាំនានា ទាក់ទងនឹងការអនុវត្តច្បាប់របស់គ្រឹះស្ថានរួមមានការត្រួតពិនិត្យលើប្រសិទ្ធភាពនៃការប្រកាន់ខ្ជាប់នូវការអនុវត្តន៍លើគោលការណ៍ដែលមានស្រាប់ជាមួយនឹងបញ្ហានានាទាំងខាងក្នុង និងក្រៅពាក់ព័ន្ធនឹងការប្រតិបត្តិតាម និងការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាម។

ក្នុងគោលដៅវាស់វែង និងត្រួតពិនិត្យលើសមត្ថភាព និងបទពិសោធន៍ការងាររបស់អ្នកទទួលខុសត្រូវផ្នែកប្រតិបត្តិតាម បានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ដោយត្រូវមានវិញ្ញាបនបត្រការអនុលោមតាមបទប្បញ្ញត្តិទទួលស្គាល់ពីវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ហើយបានបន្តវិញ្ញាបនបត្រនេះនៅរៀងរាល់ ៣ឆ្នាំម្តង ដែលបានទទួលស្គាល់ជាថ្មី នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ ដោយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ។ បន្ថែមលើនោះទៀត នាយកដ្ឋានគ្រប់គ្រងហានិភ័យ ច្បាប់ និងប្រតិបត្តិតាម ត្រូវទទួលខុសត្រូវត្រួតពិនិត្យលើការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលត្រូវរាយការណ៍ និងសហការប្រតិបត្តិការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជារបស់ធនាគារជាតិនៃកម្ពុជាផងដែរ។

# សវនកម្មផ្ទៃក្នុង

## គណៈកម្មាធិការសវនកម្ម (កម្រិតក្រុមប្រឹក្សាភិបាល)

ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតគណៈកម្មាធិការ ចំនួន ២ រួមមាន គណៈកម្មាធិការសវនកម្មផ្ទៃក្នុង និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។

គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីធានាអភិបាលកិច្ចសាជីវកម្មប្រកបដោយសុវត្ថិភាព និងត្រូវផ្តល់អំណាចពិសេសចាំបាច់ដែលត្រូវបានកំណត់ក្នុងគោលការណ៍ ដើម្បីសម្រេចគោលដៅរបស់ខ្លួន។ អំណាចតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្មផ្ទៃក្នុងមានភាពទូលំទូលាយ និងគោរពតាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា ១៣១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក៏ដូចជាមាត្រា ៨ នៃប្រកាសលេខ ធ៧-០៨-២១១ ស្តីពីអភិបាលកិច្ចរបស់ធនាគារ និងហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រធានគណៈកម្មាធិការនេះ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ហើយក៏ត្រូវឆ្លើយនឹងសំណួរទាំងអស់ពីភាគទុនិកនៅក្នុងកិច្ចប្រជុំ។

## ភារកិច្ច និងការទទួលខុសត្រូវ

- ពិនិត្យ និងអនុម័តទៅលើលក្ខខណ្ឌនៃកម្មវិធីសវនកម្មផ្ទៃក្នុង និងផែនការប្រចាំឆ្នាំ រួមទាំងគោលបំណង វិសាលភាព និងតារាងកាលវិភាគ
- ពិនិត្យមើលបញ្ហាទាំងឡាយណា ដែលអាចជះឥទ្ធិពលដល់ឯករាជ្យភាពរបស់សវនករផ្ទៃក្នុង
- ពិនិត្យ និងអនុម័តគោលការណ៍ និងនីតិវិធី
- ពិនិត្យមើលការរកឃើញ និងការតាមដានរបស់សវនករផ្ទៃក្នុង រួមទាំងចំណុចសំខាន់ៗ ដែលមិនយល់ស្របគ្នារវាងគណៈគ្រប់គ្រង និងសវនករផ្ទៃក្នុងពាក់ព័ន្ធនឹងការត្រួតពិនិត្យ
- ធានាថាការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងបើកចំហមានការចូលរួមក្នុងចំណោមគណៈកម្មាធិការសវនកម្ម សវនករឯករាជ្យ និង

សវនកម្មខាងក្នុង
• ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម អាចចូលជួបសវនករផ្ទៃក្នុង និងប្រធានផ្នែក/នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដោយមិនមានការចូលរួមពីគណៈគ្រប់គ្រង
• ប្រាប់ពីការរំពឹងទុករបស់គណៈកម្មាធិការសវនកម្ម ទៅកាន់សវនករផ្ទៃក្នុងឱ្យបានដឹងជាលាយលក្ខណ៍អក្សរ
• ទទួល និងពិនិត្យមើលរបាយការណ៍របស់សវនករផ្ទៃក្នុង ពាក់ព័ន្ធនឹងគុណភាព និងភាពទាន់ពេលវេលាកំណត់
• ពិនិត្យ និងតាមដានការអនុវត្តតាមអនុសាសន៍លើការរកឃើញរបស់សវនករផ្ទៃក្នុង
• តាមដាន និងពិនិត្យឡើងវិញនូវគុណភាពនៃការផ្តល់សេវាកម្មសវនកម្មផ្ទៃក្នុង
• វាយតម្លៃដំណើរការរបស់គ្រឹះស្ថាន ដើម្បីតាមដាន និងវាយតម្លៃប្រសិទ្ធភាពរបស់សវនករផ្ទៃក្នុង
• ពិនិត្យមើលការរៀបចំផែនការសកម្មភាពរបស់សវនកម្មផ្ទៃក្នុង សវនកម្មឯករាជ្យ និងការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

## ការប្រជុំ និងសមាជិកភាព

គណៈកម្មាធិការត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ដោយមានសមាជិកយ៉ាងតិចបំផុត ៣ រូប។ ប្រធាននៃគណៈកម្មាធិការនេះ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យរបស់គ្រឹះស្ថាន ហើយគ្រប់សមាជិកទាំងអស់ក៏ត្រូវតែមានភាពឯករាជ្យលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនផងដែរ។ សមាជិកគណៈកម្មាធិការសវនកម្មរួមមានដូចខាងក្រោម៖

| | | |
|---|---|---|
| • លោក ហ៊ាន សុខុម | សមាជិក្រុមប្រឹក្សាភិបាលឯករាជ្យ | ប្រធាន |
| • លោក ជូនីជី សាសាគី | សមាជិកក្រុមប្រឹក្សាភិបាល | សមាជិក |
| • លោក ខាំ រឿន | ប្រធានផ្នែកសវនកម្មផ្ទៃក្នុង | សមាជិក/លេខាធិការ |

កិច្ចប្រជុំគណៈកម្មាធិការសវនកម្មផ្ទៃក្នុង អាចប្រព្រឹត្តទៅបានក្នុងករណីមានការស្នើឡើងដោយប្រធាន ឬតាមសំណើរបស់សមាជិក ឬតាមសំណើរបស់សវនករផ្ទៃក្នុង ឬសវនករឯករាជ្យ (ខាងក្រៅ) ប្រសិនបើចាំបាច់។ សេចក្តីបញ្ជាក់ពីទីកន្លែង ពេលវេលា និងរបៀបវារៈកិច្ចប្រជុំដែលត្រូវពិភាក្សាត្រូវបញ្ជូនទៅកាន់គ្រប់សមាជិក និងអ្នកពាក់ព័ន្ធដែលត្រូវចូលរួមប្រជុំឱ្យបានយ៉ាងតិចណាស់មុន ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ ឯកសារពាក់ព័ន្ធត្រូវផ្ញើទៅកាន់គ្រប់សមាជិក និងអ្នកចូលរួមផ្សេងទៀតក្នុងពេលជាមួយគ្នា។ កិច្ចប្រជុំវិសាមញ្ញអាចប្រព្រឹត្តទៅបានតាមការពិនិត្យថាសមស្រប ប៉ុន្តែកិច្ចប្រជុំសាមញ្ញត្រូវធ្វើឡើងយ៉ាងតិច ២ (ពីរ) ដងក្នុង១ (មួយ) ឆ្នាំ គឺនៅក្នុងខែមិថុនា និងខែធ្នូនៃឆ្នាំនីមួយៗទៅតាមស្ថានភាពជាក់ស្តែង។ ជាក់ស្តែងក្នុងឆ្នាំ២០២៥ កិច្ចប្រជុំគណៈកម្មាធិការនេះ បានប្រព្រឹត្តទៅបានចំនួន ១លើកនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ តាមរយៈការជួបប្រជុំផ្ទាល់។

សវនកម្មផ្ទៃក្នុង ត្រូវតែជាផ្នែកមួយឯករាជ្យក្នុងការត្រួតពិនិត្យ និងរាយការណ៍លើការអនុវត្តទូទៅរបស់ស្ថាប័ន។ ផ្នែកសវនកម្មផ្ទៃក្នុងរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១៧ ទទួលខុសត្រូវដោយប្រធានផ្នែកសវនកម្មផ្ទៃក្នុង ហើយត្រូវបានផ្លាស់ប្តូរ និងបានទទួលស្គាល់ជាថ្មីពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០។ ប្រធានផ្នែកសវនកម្មផ្ទៃក្នុង នឹងទទួលខុសត្រូវក្នុងការធ្វើសវនកម្មផ្ទៃក្នុង និងត្រួតពិនិត្យប្រតិបត្តិការនានានៅក្នុងគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ដោយត្រូវអនុវត្តទៅតាមផែនការសវនកម្ម ធ្វើបច្ចុប្បន្នភាពកម្មវិធីសវនកម្ម និងផ្តល់ការបណ្តុះបណ្តាលបុគ្គលិក ដែលជាតម្រូវការចាំបាច់ដើម្បីបង្កើនគុណភាពសវនកម្មរបស់ខ្លួន។ តាមផែនការរបស់សវនកម្មផ្ទៃក្នុងយ៉ាងហោចណាស់ ២ដងក្នុង១ឆ្នាំ ត្រូវចុះធ្វើសវនកម្មនៅការិយាល័យសាខា និង ១ដងក្នុងមួយឆ្នាំតាមនាយកដ្ឋានសំខាន់ៗ។ ប្រធានផ្នែកសវនកម្មផ្ទៃក្នុងត្រូវត្រួតពិនិត្យរាល់ប្រតិបត្តិការរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី និងរាយការណ៍ដោយឯករាជ្យ និងដោយផ្ទាល់ទៅគណៈកម្មាធិការសវនកម្មផ្ទៃក្នុងក្នុងកម្រិតក្រុមប្រឹក្សាភិបាល។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២៥ សវនកម្មផ្ទៃក្នុង ក៏បានរាយការណ៍នូវរបាយការណ៍សវនកម្មផ្ទៃក្នុងរបស់ខ្លួន ទៅសមាជិកក្រុមប្រឹក្សាភិបាលពីការអនុវត្តការងារ និងកំហុសឆ្គងនានានៃប្រតិបត្តិការគ្រឹះស្ថានរបស់គណៈគ្រប់គ្រង នាយកដ្ឋាន និងការិយាល័យសាខានីមួយៗ។

# សមិទ្ធផលអាជីវកម្ម

- សមិទ្ធផលឥណទានតាមវិស័យ
- សមិទ្ធផលឥណទានតាមផលិតផល
- ចំណាត់ថ្នាក់ប្រភេទឥណទាន
- ចំណាត់ថ្នាក់ប្រភេទផលិតផល

# សមិទ្ធផលឥណទានតាមវិស័យ

## ចំនួនគណនី

| វិស័យ | ២០២៥ | ២០២៤ |
|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៤១ | ៣៤ |
| ជំនួញ និងពាណិជ្ជកម្ម | ២៣៩ | ១៥៦ |
| សិប្បកម្ម | ៥ | - |
| សំណង់ | ៥៨៩ | ៣៨៨ |
| ការដឹកជញ្ជូន | ២៨ | ២៥ |
| សេវាកម្ម | ៣៩ | ៣៦ |
| ប្រើប្រាស់ក្នុងគ្រួសារ | ៣០៦ | ៣៧៦ |
| ប្រភេទផ្សេងៗទៀត | - | - |

## ផលបត្រឥណទានសរុប

| វិស័យ | ២០២៥ | ២០២៤ |
|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣៩០.៥២៨ | ៧១៨.៧០៨ |
| ជំនួញ និងពាណិជ្ជកម្ម | ៣.៣៦៩.៩៧០ | ២.៣៤១.២១៥ |
| សិប្បកម្ម | ៦២.២៣៨ | - |
| សំណង់ | ៧.៩១៨.៨៧៤ | ៥.១៥៩.៩២២ |
| ការដឹកជញ្ជូន | ៤២៨.៦៥៣ | ២៤៦.៤០៩ |
| សេវាកម្ម | ៥៥១.៨៥៨ | ៥០៣.១៧២ |
| ប្រើប្រាស់ក្នុងគ្រួសារ | ២.១៥៣.៦២២ | ៥.៨២៩.១៩៤ |
| ប្រភេទផ្សេងៗទៀត | - | - |

# សមិទ្ធផលឥណទានតាមផលិតផល

## ចំនួនគណនី

| ផលិតផល | ២០២៥ | ២០២៤ |
|---|---|---|
| ឥណទានអាជីវកម្ម | ២៧០ | ២៣៨ |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ៦៣៦ | ៥០៦ |
| ឥណទានកសិកម្ម | ៣៨ | ៤០ |
| ឥណទានគេហដ្ឋាន | ១៦៨ | ១៧៤ |
| ឥណទានបុគ្គលិក | ៣៥ | ៣៦ |
| ឥណទានសិក្សា | - | ៣ |
| ឥណទាននិយោជិត | ១៩ | ១៨ |
| ឥណទានយានយន្ត និងបរិក្ខារប្រើប្រាស់ | ៨១ | - |

## ផលបត្រឥណទានសរុប

| ផលិតផល | ២០២៥ | ២០២៤ |
|---|---|---|
| ឥណទានអាជីវកម្ម | ៣.៩៤០.០៨០ | ៤.១០៨.៨៧៧ |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ៦.៩៤៨.៤៨៣ | ៦.៤៣០.៣០៤ |
| ឥណទានកសិកម្ម | ៣៤២.៥៩៩ | ៤៤១.៧៣២ |
| ឥណទានគេហដ្ឋាន | ៣.១៨១.៧២២ | ៣.៤៩៨.៨៦៦ |
| ឥណទានបុគ្គលិក | ២៥៨.៥៩៩ | ២៩៤.២១៤ |
| ឥណទានសិក្សា | - | ២.៤៦០ |
| ឥណទាននិយោជិត | ៣៣.៩៣២ | ២២.១៦៧ |
| ឥណទានយានយន្ត និងបរិក្ខារប្រើប្រាស់ | ១៧០.៣២៨ | - |

# ចំណាត់ថ្នាក់ប្រភេទឥណទាន

## ផលបត្រឥណទានសរុប

| ប្រភេទ | ២០២៥ | ២០២៤ | កំណើន (%) |
|---|---|---|---|
| ឥណទានខ្នាតតូចបំផុត | ៧៦០.២៩៦ | ៣៤៣.៩៨១ | ១២១% |
| ឥណទានខ្នាតតូច | ៦.២៩៧.៨២៣ | ៥.៨៥០.១៩៤ | ៨% |
| ឥណទានខ្នាតមធ្យម | ៧.១១៨.២១៨ | ៧.៧៤៦.៨៤៦ | (៨%) |
| ឥណទានខ្នាតធំ | ៦៩៩.៤០៧ | ៨៥៧.៦៤៩ | (១៨%) |

# ចំណាត់ថ្នាក់ប្រភេទផលិតផល

## ផលបត្រឥណទានសរុប

| ផលិតផល | ២០២៥ | ២០២៤ | កំណើន (%) |
|---|---|---|---|
| ឥណទានអាជីវកម្ម | ៣.៩៤០.០៨០ | ៤.១០៨.៨៧៧ | (៤%) |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ៦.៩៤៨.៤៨៣ | ៦.៤៣០.៣០៤ | ៨% |
| ឥណទានកសិកម្ម | ៣៤២.៥៩៩ | ៤៤១.៧៣២ | (២២%) |
| ឥណទានគេហដ្ឋាន | ៣.១៨១.៧២២ | ៣.៤៩៨.៨៦៦ | (៩%) |
| ឥណទានបុគ្គលិក | ២៥៨.៥៩៩ | ២៩៤.២១៤ | (១២%) |
| ឥណទានសិក្សា | - | ២.៤៦០ | (១០០%) |
| ឥណទាននិយោជិត | ៣៣.៩៣២ | ២២.១៦៧ | ៥៣% |
| ឥណទានយានយន្ត និងបរិក្ខារប្រើប្រាស់ | ១៧០.៣២៨ | - | - |

# ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

- ការបណ្តុះបណ្តាលខាងក្នុង
- ការបណ្តុះបណ្តាលខាងក្រៅ
- សិក្ខាសាលាប្រចាំឆ្នាំ

# ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក គឺជាសកម្មភាពចម្បងក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ដូចជាពង្រីកដល់ការយល់ដឹង បង្កើនចំណេះជំនាញបន្ថែម និងទស្សនៈថ្មីៗដល់បុគ្គលិក ដើម្បីឲ្យការអនុវត្តការងាររបស់ពួកគេមានប្រសិទ្ធិភាពខ្ពស់ រួមទាំងជួយបង្កើនដល់ការរីកចម្រើនទាំងបុគ្គលិកផ្ទាល់ និងគ្រឹះស្ថានផងដែរ។ ថ្នាក់ដឹកនាំ ហ្វូតាបា តែងជំរុញលើកទឹកចិត្តដល់នាយកដ្ឋានធនធានមនុស្ស និង រដ្ឋបាល ធ្វើការសម្របសម្រួលជាមួយនាយកដ្ឋានផ្សេងៗ រៀបចំផ្តល់វគ្គហ្វឹកហ្វឺនជូនបុគ្គលិកយ៉ាងទៀងទាត់ ទាំងបុគ្គលិកចូលថ្មី និងបុគ្គលិកកំពុងបម្រើការងារ ដែលរួមមានដូចខាងក្រោម៖

- ការបណ្តុះបណ្តាលខាងក្នុង

សម្រាប់ឆ្នាំ២០២៥នេះ ការបណ្តុះបណ្តាលខាងក្នុងត្រូវបានរៀបចំឡើងមានចំនួនសរុប ១៨លើក ដែលក្នុងនោះបុគ្គលិកចូលថ្មីមានចំនួន ៩លើក និងបុគ្គលិកំពុងបម្រើការងារមានចំនួន ៩លើក ផងដែរ។



កម្រងរូបភាពការបណ្តុះបណ្តាលខាងក្នុង

- ការបណ្តុះបណ្តាលខាងក្រៅ

ការជំរុញឱ្យថ្នាក់ដឹកនាំ និងបុគ្គលិកចូលរួមការបណ្តុះបណ្តាលខាងក្រៅ គឺជាយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន ដើម្បីបង្កើនចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗរបស់បុគ្គលិក ក្នុងគោលបំណងធ្វើឲ្យការងារមានប្រសិទ្ធភាព លើកកម្ពស់អាជីពបង្កើនសមត្ថភាពមកអភិវឌ្ឍការងារនៅក្នុងគ្រឹះស្ថាន ដើម្បីឱ្យមានការរីកចម្រើនទៅមុខប្រកបដោយប្រសិទ្ធភាព គឺជាតម្រូវការចាំបាច់មិនអាចខ្វះបាន ដែលថ្នាក់ដឹកនាំរបស់ ហ្វូតាបា តែងជំរុញលើកទឹកចិត្តអនុវត្តជាប្រចាំ។ ជាក់ស្តែងសម្រាប់ឆ្នាំ២០២៥នេះ ហ្វូតាបា បានចាត់បញ្ជូនថ្នាក់ដឹកនាំ និងបុគ្គលិកចូលរួមការវគ្គហ្វឹកហ្វឺនខាងក្រៅ ក៏ដូចជាសិក្ខាសាលាផ្សេងៗ មានចំនួនសរុប ១១លើក។



កម្រងរូបភាពការបណ្តុះបណ្តាលខាងក្រៅ

- សិក្ខាសាលាប្រចាំឆ្នាំ

សិក្ខាសាលាប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងដោយមានគោលបំណងចម្បង ដើម្បីបង្កើតឱកាសដ៏ល្អសម្រាប់ថ្នាក់ដឹកនាំទាំងអស់បានជួបជុំគ្នា និងចែករំលែកអំពីរបាយការណ៍លទ្ធផលអាជីវកម្មដែលសម្រេចបានជាក់ស្តែងក្នុង រយៈពេលមួយឆ្នាំកន្លងមក ព្រមទាំងពិភាក្សា និងកំណត់ផែនការយុទ្ធសាស្ត្រ ថ្មីៗបន្ថែម សម្រាប់អនុវត្ត និងអភិវឌ្ឍន៍គ្រឹះស្ថានឱ្យទទួលបានជោគជ័យ និងភាពរីកចម្រើនបន្តទៅមុខ។ ក្នុងឱកាសនោះផងដែរ មានវត្តមានដ៏ខ្ពង់ខ្ពស់ពីលោកប្រធានក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងទាំងអស់ ដែលបានញ៉ាំងឱ្យកម្មវិធីសិក្ខាសាលាប្រចាំឆ្នាំ២០២៥ កាន់តែមានភាពកក់ក្តៅ សាមគ្គីភាព និងស្និទ្ធស្នាល។

គួរបញ្ជាក់ផងដែរថា សិក្ខាសាលាប្រចាំឆ្នាំ២០២៥នេះ ត្រូវបានរៀបចំឡើងនៅប្រទេសម៉ាឡេស៊ី និងប្រទេសសិង្ហបុរី ក្រោមប្រធានបទ «ការសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងការធ្វើផែនការអាជីវកម្មសម្រាប់ឆ្នាំ២០២៦» និង «ផែនការសកម្មភាព (POA) ឆ្នាំ២០២៦» សម្រាប់ថ្នាក់គ្រប់គ្រងរបស់ គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ កម្មវិធីនេះ មានការចូលរួមពីលោកប្រធានក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងសរុបចំនួន ១៨នាក់។













កម្រងរូបភាពសិក្ខាសាលាប្រចាំឆ្នាំ

# របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ

- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់សវនករឯករាជ្យ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍លទ្ធផលលម្អិត
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
- របាយការណ៍លំហូរសាច់ប្រាក់

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួនដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

## សកម្មភាពចម្បងៗ

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុជាសាធារណៈទៅសហគ្រាសធុនតូច និងមធ្យម និងឯកត្តជនតាមរយៈការិយាល័យកណ្តាល និងសាខា ចំនួន៤ ផ្សេងទៀតដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ ព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនោះទេ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ចំណេញមុនដកពន្ធ | ៣៧៥.៦៨៥ | ១.៥០៦.៨៧២ | ៤១៤.៣០៥ | ១.៦៨៦.៦៣៦ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១៤៣.៥៦០) | (៥៧៥.៨១៩) | (១០៧.២៨៧) | (៤៣៦.៧៦៥) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២៣២.១២៥ | ៩៣១.០៥៣ | ៣០៧.០១៨ | ១.២៤៩.៨៧១ |

## ភាគលាភ

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

## ដើមទុន

ដើមទុនដែលបានបង់របស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានចំនួន ៧.០០០.០០០ ដុល្លារអាមេរិក (២០២៤៖ ៧.០០០.០០០ ដុល្លារអាមេរិក) ដែលក្នុងនោះក្នុងមួយភាគហ៊ុនស្មើនឹង ១.០០០ ដុល្លារអាមេរិក។ សូមមើលកំណត់សម្គាល់ទី១៤ សម្រាប់ភាគហ៊ុន និងរចនាសម្ព័ន្ធភាគហ៊ុនលម្អិតរបស់ក្រុមហ៊ុន។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធនត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឱ្យមានការលុបបំបាត់ចោលឥណទានអាក្រក់ ឬការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជា

មិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

### វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឱ្យប៉ះពាល់ដល់វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

### បំណុលយថាភាព

នាថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានៈ

(ក) ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

### ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

### ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

### ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឱ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយ នៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះមានរាយនាមដូចខាងក្រោមៈ

| | |
|---|---|
| ១. លោក **ច្រឹក ផល្លី** | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. លោក **ជូនីជី សាសាគី** | អភិបាល |
| ៣. លោក **ង៉ែត សុវណ្ណារ៉ូ** | អភិបាលឯករាជ្យ |
| ៤. លោក **ហ៊ាន សុខុម** | អភិបាលឯករាជ្យ |

### ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

មិនមានសមាជិកក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុនដោយផ្ទាល់ឬ ដោយប្រយោល នៅក្នុងការិយបរិច្ឆេទនេះឡើយ។

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

មិនថានៅចុងការិយបរិច្ឆេទឬនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុន

ជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់កុម្រហ៊ុន ឬសាជីវកម្មដទៃ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលក្នុងចំនួនសរុបនៃលាភការដែលបានទទួល ឬកំណត់នឹងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយកុម្រហ៊ុនជាមួយក្រុមប្រឹក្សាភិបាល ឬដោយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនផ្សេង ដែលមានក្រុមប្រឹក្សាភិបាលជាសមាជិកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើនជាងអ្វីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃ កម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហៅកាត់ថា (“CIFRS for SMEs”)។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។

(ខ) អនុលោមទៅតាម CIFRS for SMEs ឬប្រសិនបើប្រាស់ចាកពីនេះដើម្បីបង្ហាញពីភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់ និងកំណត់ចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនចំពោះការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃស្តង់ដាគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រទី១០ ដល់ ៥២ ថាបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលសុី នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាម CIFRS for SMEs។

*ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។*

FUTABA MICROFINANCE PLC.
KINGDOM OF CAMBODIA

**លោក ច្រឹក ផល្លី**

***ប្រធានក្រុមប្រឹក្សាភិបាល***

**រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦**

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិករបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងរបាយការណ៍លទ្ធផលលម្អិតរបាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រទី ១០ ដល់ ៥២។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវ ក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃ ទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហៅកាត់ថា ( “CIFRS for SMEs” )។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវ របស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុនស្របតាមតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខ័ណ្ឌទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗស្របតាមតម្រូវការទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋាន ក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមថ្ងៃចេញរបាយការណ៍របស់សវនករមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅទំព័រ ១ ដល់ទី ៥ ចំណែកឯរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនរំពឹងថានឹងផ្តល់ឱ្យយើងខ្ញុំក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនបានបញ្ចេញការសន្និដ្ឋានជាក់លាក់បន្ថែមលើនេះដែរ។ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើង ខ្ញុំគឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះមានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើផ្អែកតាមការងារដែលយើងខ្ញុំបានធ្វើមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្ម អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម CIFRS for SMEs ហើយនឹងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិន បើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យលើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ចមានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំគឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ ការបង្ហាញខុសជាសារវន្ត អាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្ម អន្តរជាតិនៃកម្ពុជាយើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏បាន៖

. ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាង ដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
. ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
. ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោអ្នកគ្រប់គ្រង។
. ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឱ្យបញ្ឈប់នូវនិរន្តរភាពនៃអាជីវកម្ម។
. វាយតម្លៃលើការបង្ហាញរចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។
យើងខ្ញុំបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ចំពោះកត្តាពាក់ព័ន្ធនឹងសវនកម្មរួមមានជាអាទិ៍ វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាសវនកម្មជាសារវន្ត រួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **អេហ្វអាយអាយ & អឹសូស៊ីអេត**

**សេខ ចាន់ថន**
*ដៃគូសវនករ*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទ្រព្យសកម្ម | | | | |
| សាច់ប្រាក់ក្នុងដៃ | ៣៣.៨៩៨ | ១៣៦.០៣៣ | ១៧.៩៦៧ | ៧២.៣១៧ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅ ធនាគារជាតិនៃកម្ពុជា | ៣៥៣.៧០៨ | ១.៤១៩.៤៣០ | ៣៦៤.៦៧០ | ១.៤៦៧.៧៩៧ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | ១៦៣.១៦៥ | ៦៥៤.៧៨១ | ៣៤.០០០ | ១៣៦.៨៥០ |
| ឥណទានផ្តល់ដល់អតិថិជន | ១៤.៨៧៥.៧៤៣ | ៥៩.៦៩៦.៣៥៧ | ១៤.៧៩៨.៦២០ | ៥៩.៥៦៤.៤៤៦ |
| ទ្រព្យសកម្មផ្សេងៗ | ២៩០.០៦១ | ១.១៦៤.០១៥ | ២១៦.៧៩៤ | ៨៧២.៥៩៦ |
| ទ្រព្យ និងបរិក្ខារ | ១៦៧.២៤៨ | ៦៧១.១៦៦ | ១១៧.០១៦ | ៤៧០.៩៨៩ |
| ទ្រព្យសកម្មអរូបី | ២.៨២២ | ១១.៣២៥ | ៤១២ | ១.៦៥៨ |
| **ទ្រព្យសកម្មសរុប** | **១៥.៨៨៦.៦៤៥** | **៦៣.៧៥៣.១០៧** | **១៥.៥៤៩.៤៧៩** | **៦២.៥៨៦.៦៥៣** |
| បំណុល និងមូលធន | | | | |
| បំណុល | | | | |
| បំណុលផ្សេងៗ | ៧៧.៦៧៥ | ៣១១.៧១០ | ១១៦.១៨៥ | ៤៦៧.៦៤៤ |
| បំណុលពន្ធអប្បបរមា | ១.៧៤៩ | ៧.០១៩ | ១.៧៥៨ | ៧.០៧៦ |
| គណនីត្រូវទូទាត់ឱ្យភាគទុនិក | ៥.៥៣៧.១៨២ | ២២.២២០.៧១១ | ៥.៥៣៧.១៨២ | ២២.២៨៧.១៥៨ |
| ពន្ធពន្យារជាបំណុលសុទ្ធ | ៥១០.០៥០ | ២.០៤៦.៨៣១ | ៣៦៦.៤៩០ | ១.៤៧៥.១២២ |
| **បំណុលសរុប** | **៦.១២៦.៦៥៦** | **២៤.៥៨៦.២៧១** | **៦.០២១.៦១៥** | **២៤.២៣៧.០០០** |
| មូលធន | | | | |
| ដើមទុន | ៧.០០០.០០០ | ២៨.០០០.០០០ | ៧.០០០.០០០ | ២៨.០០០.០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ២.៨៩២.៨៨៨ | ១១.៧៨៥.១៥៧ | ២.៥០៨.៩៩០ | ១០.២៤៥.៣៤២ |
| ប្រាក់( ខាតបង្គរ )/ចំណេញរក្សាទុក | ( ១៣២.៨៩៩ ) | ( ៥៥១.៥២៩ ) | ១៨.៨៧៤ | ៥៧.២៣៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ( ៦៦.៧៩២ ) | - | ៤៧.០៧៨ |
| **មូលធនសរុប** | ៩.៧៥៩.៩៨៩ | ៣៩.១៦៦.៨៣៦ | ៩.៥២៧.៨៦៤ | ៣៨.៣៤៩.៦៥៣ |
| **បំណុល និងមូលធនសរុប** | **១៥.៨៨៦.៦៤៥** | **៦៣.៧៥៣.១០៧** | **១៥.៥៤៩.៤៧៩** | **៦២.៥៨៦.៦៥៣** |

# របាយការណ៍លទ្ធផលលម្អិត

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ១.៩៤៤.២១៦ | ៧.៧៩៨.២៥០ | ១.៩២៧.១៣៧ | ៧.៨៤៥.៣៧៥ |
| ចំណាយលើការប្រាក់ | (៨៣.០៥៨) | (៣៣៣.១៤៦) | (៨៨.៥០២) | (៣៦០.២៩២) |
| ចំណូលពីការប្រាក់សុទ្ធ | ១.៨៦១.១៥៨ | ៧.៤៦៥.១០៤ | ១.៨៣៨.៦៣៥ | ៧.៤៨៥.០៨៣ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ៨២.៩៧៩ | ៣៣២.៨២៩ | ៨៧.១២២ | ៣៥៤.៦៧៤ |
| ចំណូលប្រតិបត្តិការសរុប | ១.៩៤៤.១៣៧ | ៧.៧៩៧.៩៣៣ | ១.៩២៥.៧៥៧ | ៧.៨៣៩.៧៥៧ |
| ចំណាយបុគ្គលិក | (៨៦៥.៨៤១) | (៣.៤៧២.៨៨៨) | (៨៩៥.២៣៤) | (៣.៦៤៤.៤៩៨) |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាល | (៥៧៨.៤១០) | (២.៣២០.០០៣) | (៤៧៨.៥៧៥) | (១.៩៤៨.២៧៩) |
| ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | (១២៤.២០១) | (៤៩៨.១៧០) | (១១៧.៥៨៣) | (៤៧៨.៦៨០) |
| ចំណាយពន្ធអប្បបរមា | - | - | (២០.០៦០) | (៨១.៦៦៤) |
| ប្រាក់ចំណេញមុនដកពន្ធ | ៣៧៥.៦៨៥ | ១.៥០៦.៨៧២ | ៤១៤.៣០៥ | ១.៦៨៦.៦៣៦ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១៤៣.៥៦០) | (៥៧៥.៨១៩) | (១០៧.២៨៧) | (៤៣៦.៧៦៥) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២៣២.១២៥ | ៩៣១.០៥៣ | ៣០៧.០១៨ | ១.២៤៩.៨៧១ |
| លទ្ធផលលម្អិតផ្សេងៗ | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១១៣.៨៧០) | - | (៥៦៧.៣៧៥) |
| សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ | ២៣២.១២៥ | ៨១៧.១៨៣ | ៣០៧.០១៨ | ៦៨២.៤៩៦ |

# របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្ដូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ៧.០០០.០០០ | ២៨.០០០.០០០ | ១.៤៤១.៣៨២ | ៥.៨៩៩.១១០ | ៧៧៩.៤៦៤ | ៣.១៩៣.៥៩៤ | - | ៦១៤.៤៥៣ | ៩.២២០.៨៤៦ | ៣៧.៦៦៧.១៥៧ |
| លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ៣០៧.០១៨ | ១.២៤៩.៨៧១ | - | - | ៣០៧.០១៨ | ១.២៤៩.៨៧១ |
| ការផ្ទេរ (កំណត់ឡើងវិញ) | - | - | ១.០៦៧.៦០៨ | ៤.៣៤៦.២៣២ | (១.០៦៧.៦០៨) | (៤.៣៤៦.២៣២) | - | - | - | - |
| លទ្ធផលលម្អិតផ្សេងៗ | | | | | | | | | | |
| លម្អៀងពីការប្ដូររូបិយប័ណ្ណ | - | - | - | - | - | - | - | (៥៦៧.៣៧៥) | - | (៥៦៧.៣៧៥) |
| សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ | - | - | ១.០៦៧.៦០៨ | ៤.៣៤៦.២៣២ | (៧៦០.៥៩០) | (៣.០៩៦.៣៦១) | - | (៥៦៧.៣៧៥) | ៣០៧.០១៨ | ៦៨២.៤៩៦ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (កំណត់ឡើងវិញ) | ៧.០០០.០០០ | ២៨.០០០.០០០ | ២.៥០៨.៩៩០ | ១០.២៤៥.៣៤២ | ១៨.៨៧៤ | ៩៧.២៣៣ | - | ៤៧.០៧៨ | ៩.៥២៧.៨៦៤ | ៣៨.៣៤៩.៦៥៣ |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ | ៧.០០០.០០០ | ២៨.០០០.០០០ | ២.៥០៨.៩៩០ | ១០.២៤៥.៣៤២ | ១៨.៨៧៤ | ៩៧.២៣៣ | - | ៤៧.០៧៨ | ៩.៥២៧.៨៦៤ | ៣៨.៣៤៩.៦៥៣ |
| លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ២៣២.១២៥ | ៩៣១.០៥៣ | - | - | ២៣២.១២៥ | ៩៣១.០៥៣ |
| ការផ្ទេរ | - | - | ៣៨៣.៨៩៨ | ១.៥៣៩.៨១៥ | (៣៨៣.៨៩៨) | (១.៥៣៩.៨១៥) | - | - | - | - |
| លទ្ធផលលម្អិតផ្សេងៗ | | | | | | | | | | |
| លម្អៀងពីការប្ដូររូបិយប័ណ្ណ | - | - | - | - | - | - | - | (១១៣.៨៧០) | - | (១១៣.៨៧០) |
| សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ | - | - | ៣៨៣.៨៩៨ | ១.៥៣៩.៨១៥ | (១៥១.៧៧៣) | (៦០៨.៧៦២) | - | (១១៣.៨៧០) | ២៣២.១២៥ | ៨១៧.១៨៣ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ៧.០០០.០០០ | ២៨.០០០.០០០ | ២.៨៩២.៨៨៨ | ១១.៧៨៥.១៥៧ | (១៣២.៨៩៩) | (៥៥១.៥២៩) | - | (៦៦.៧៩២) | ៩.៧៥៩.៩៨៩ | ៣៩.១៦៦.៨៣៦ |

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២៣២.១២៥ | ៩៣១.០៥៣ | ៣០៧.០១៨ | ១.២៤៩.៨៧១ |
| | | | | |
| និយ័តភាពលើ៖ | | | | |
| ចំណាយពន្ធអប្បបរមា | - | - | ២០.០៦០ | ៨១.៦៦៤ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៤៣.៥៦០ | ៥៧៥.៨១៩ | ១០៧.២៨៧ | ៤៣៦.៧៦៥ |
| ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | ១២៤.២០១ | ៤៩៨.១៧០ | ១១៧.៥៨៣ | ៤៧៨.៦៨០ |
| រំលស់ | ៤៦.៥៨៥ | ១៨៦.៨៥២ | ៥៦.៥៨៩ | ២៣០.៣៧៣ |
| ចំណេញលើការលក់ទ្រព្យ និងបរិក្ខារ | ៨.២២៣ | ៣២.៩៨២ | (៣៧០) | (១.៥០៦) |
| ការលុបចោលទ្រព្យ និងបរិក្ខារ | - | - | ១២.៤៤៩ | ៥០.៦៨០ |
| | ៥៥៤.៦៩៤ | ២.២២៤.៨៧៦ | ៦២០.៦១៦ | ២.៥២៦.៥២៧ |
| | | | | |
| បម្រែបម្រួលនូវ៖ | | | | |
| ឥណទានផ្តល់ដល់អតិថិជន | (១៨៦.៧៣០) | (៧៤៨.៩៧៤) | (៥៣៣.១២៧) | (២.១៧០.៣៦០) |
| ទ្រព្យសកម្មផ្សេងៗ | (៦៧.៦១៣) | (២៧១.១៩៦) | (៤៣.៣៩៨) | (១៧៦.៦៧៣) |
| បំណុលផ្សេងៗ | (៣៨.៥១០) | (១៥៤.៤៦៤) | ៥៤.១៥៤ | ២២០.៤៦១ |
| **សាច់ប្រាក់ទទួលបានពី/(ប្រើប្រាស់ក្នុង)ប្រតិបត្តិការ** | **២៦១.៨៤១** | **១.០៥០.២៤២** | **៩៨.២៤៥** | **៣៩៩.៩៥៥** |
| | | | | |
| ពន្ធអប្បបរមា និងពន្ធលើប្រាក់ចំណេញដែលបានបង់ | (២០.២៥៧) | (៨១.២៥១) | (១៩.៩០២) | (៨១.០២១) |
| **សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង)សកម្មភាពប្រតិបត្តិការ** | **២៤១.៥៨៤** | **៩៦៨.៩៩១** | **៧៨.៣៤៣** | **៣១៨.៩៣៤** |
| | | | | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | - | - | ៣៧០ | ១.៥០៦ |
| ការទិញទ្រព្យ និងបរិក្ខារ | (១០៤.០២៩) | (៤១៧.២៦០) | (៧.២៦៩) | (២៩.៥៩២) |
| ការទិញទ្រព្យសកម្មអរូបី | (៣.៤២១) | (១៣.៧២២) | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | **(១០៧.៤៥០)** | **(៤៣០.៩៨២)** | **(៦.៨៩៩)** | **(២៨.០៨៦)** |
| | | | | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| ប្រាក់កម្ចីបន្ថែម | - | - | ៥០០.០០០ | ២.០៣៥.៥០០ |
| ការទូទាត់សងប្រាក់កម្ចី | - | - | (១.០០០.០០០) | (៤.០៧១.០០០) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | **-** | **-** | **(៥០០.០០០)** | **(២.០៣៥.៥០០)** |
| | | | | |
| ការថយចុះសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៣៤.១៣៤ | ៥៣៨.០០៩ | (៤២៨.៥៥៦) | (១.៧៤៤.៦៥២) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី ១ ខែមករា | ៦៦.៦៣៧ | ២៦៨.២១៤ | ៤៩៥.១៩៣ | ២.០២២.៨៦៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៥២៩) | - | (៩.៩៩៨) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី ៣១ ខែធ្នូ** | **២០០.៧៧១** | **៨០៥.៦៩៤** | **៦៦.៦៣៧** | **២៦៨.២១៤** |

# ដៃគូសហប្រតិបត្តិការ

## ដៃគូ

## ម្ចាស់កម្មវិធី

## រាល់ មតិរិះគន់ ឬ បណ្តឹងតវ៉ា ផ្សេងៗ
## សូមទំនាក់ទំនងមកកាន់លេខ

០៧០ ២២៩ ៣៣៣

០១៧ ២៣៧ ៨៨៥



០៧០ ៣១៥ ៣៣៣

អាសយដ្ឋាន៖
ផ្ទះលេខ៤៧ មហាវិថីយោធពលខេមរភូមិន្ទ ភូមិ១
សង្កាត់ទូលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ.
០២៣ ២២៤ ៣៣៣
info@futabamfi.com.kh Futaba Microfinance Plc.